សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ
LICADHO
CAMBODIAN LEAGUE FOR THE PROMOTION AND DEFENSE OF HUMAN RIGHTS
ផ្ទះលេខ១៦ ផ្លូវលេខ៩៩ ប្រអប់សំបុត្រលេខ៤៩៩ រាជធានីភ្នំពេញ កម្ពុជា
ទូរស័ព្ទលេខ: (+៨៥៥) ២៣ ៧២៧ ១០២/២១៦ ៦០២ អ៊ីមែល:contact@licadho-cambodia.org

# សេចក្តីសង្ខេបផ្នែកច្បាប់

# ច្បាប់ស្តីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត ដែលបានអនុវត្តចំពោះអ្នកការពារសិទ្ធិមនុស្ស អ្នកការពារសិទ្ធិដីធ្លី និងប្រជាពលរដ្ឋផ្សេងទៀត

ចេញផ្សាយខែកក្កដា ឆ្នាំ២០២២

គ្របដណ្តប់ចាប់ពីថ្ងៃទី១១ ខែមីនា ឆ្នាំ២០២១ ដល់ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២២

## សេចក្តីផ្តើម

ច្បាប់ស្តីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត (ច្បាប់កូវីដ-១៩)[១] បានបង្កឱ្យមានការរំលោភសិទ្ធិមនុស្សយ៉ាងធ្ងន់ធ្ងរក្នុងរយៈពេលមួយឆ្នាំចុងក្រោយ តាមរយៈការអនុវត្តប្រកបដោយការរើសអើងលើវិសាលភាព និងអំណាចយ៉ាងទូលំទូលាយ និងការដាក់ទណ្ឌកម្មធ្ងន់ធ្ងរហួសហេតុមួយចំនួន ។

នៅដើមឆ្នាំ២០២០ មេរោគកូវីដ-១៩ បានរីករាលដាលពាសពេញពិភពលោក និងបានបង្កើតជាជំងឺរាតត្បាតជាសកលជាលើកដំបូងក្នុងរយៈពេល១០០ ឆ្នាំចុងក្រោយ ។ ប្រទេសកម្ពុជាបានរួចផុតពីផលប៉ះពាល់ដ៏អាក្រក់បំផុតនៃវីរុសអាល់ហ្វា និងវីរុសរាតត្បាតដំបូងផ្សេងទៀតនៅក្នុងឆ្នាំទីមួយនៃជំងឺរាតត្បាតនេះ ។ ផលប៉ះពាល់នេះបានប្រែប្រួលនៅដើមឆ្នាំ២០២១ ដោយសារចំនួនករណីឆ្លងចាប់ផ្តើមកើនឡើងជាមួយនឹងការមកដល់នៃវីរុសបំបែកខ្លួនកាន់តែច្រើន ។ ជាផ្នែកមួយនៃវិធានការឆ្លើយតបរបស់ខ្លួនចំពោះការកើនឡើងនៃករណីអ្នកឆ្លង រាជរដ្ឋាភិបាលកម្ពុជា (រដ្ឋាភិបាល) បានអនុម័ត និងអនុវត្តច្បាប់កូវីដ-១៩ ។[២]

---

[១] ច្បាប់ស្តីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ផ្សេងទៀត (ច្បាប់ កូវីដ-១៩) នស/រកម/០៣២១/00៤ (១១ មីនា ២០២១) ។

[២] រដ្ឋាភិបាល ក៏បានអនុម័តច្បាប់មួយនៅក្នុងខែមេសា ឆ្នាំ២០២០ ដែលប្រើអំណាចតាមរដ្ឋធម្មនុញ្ញរបស់ព្រះមហាក្សត្រដើម្បីប្រកាសដាក់ប្រទេសក្នុងភាពអាសន្ន ។ សូមមើលមាត្រា២២ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។ ច្បាប់ស្តីពីការគ្រប់គ្រងប្រទេសជាតិស្ថិតក្នុងភាពអាសន្ន នស/រកម/0៤២០/0១៨ (២៩ មេសា ២០២០) ។ ច្បាប់ស្តីពីស្ថានភាពអាសន្នធ្លាប់ត្រូវបានរិភាគ ប៉ុន្តែមិនត្រូវបានគេយកមកប្រើប្រាស់ ដូច្នេះច្បាប់នេះមិនត្រូវបានដាក់បញ្ចូលក្នុងការវិភាគនៃច្បាប់ដែលពាក់ព័ន្ធ ព្រោះច្បាប់ទាំងនោះត្រូវបានអនុវត្តនៅក្នុងឆ្នាំមុន ។

ការវិភាគនេះនឹងលម្អិតអំពីការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរមួយចំនួន ដែលកើតឡើងតាមរយៈការអនុវត្តច្បាប់កូវីដ-១៩ និងអនុក្រឹត្យចំនួនពីរផ្សេងទៀត ដែលបង្កើតនីតិវិធីច្បាប់ដើម្បីអនុវត្តច្បាប់នេះនៅក្នុងរយៈពេលមួយឆ្នាំចុងក្រោយ ។ ការរំលោភបំពានទាំងនេះរួមមានការរឹតត្បិតលើការធ្វើដំណើរ ការជួបប្រជុំដោយសន្តិវិធី សេរីភាពក្នុងការបង្កើតសមាគម និងសេរីភាពក្នុងការបញ្ចេញមតិ ។ គោលបំណងនៃការវិភាគនេះគឺដើម្បីបញ្ជាក់ពីរបៀបដែលច្បាប់នេះមិនបានអនុលោមតាមស្តង់ដារសិទ្ធិមនុស្សជាតិ និងអន្តរជាតិ ផលប៉ះពាល់ដែលច្បាប់នេះមានចំពោះអ្នកការពារសិទ្ធិមនុស្ស និងប្រជាពលរដ្ឋដែលប្រើប្រាស់សិទ្ធិរបស់ពួកគេ និងដើម្បីផ្តល់ការជាស់តឿនអំពីគ្រោះថ្នាក់នៃការបង្កើតច្បាប់ដែលផ្តល់អំណាចទាំងស្រុង និងអំណាច ដែលគ្មានការត្រួតពិនិត្យរបស់រដ្ឋាភិបាល ក្នុងអំឡុងពេលមានវិបត្តិសុខភាពសាធារណៈ ។

ក្នុងរយៈពេលត្រឹមតែ១២ ថ្ងៃនៅដើមឆ្នាំ២០២១ រដ្ឋាភិបាលដែលកើតចេញមកពីបក្សតែមួយបានព្រាង និងអនុម័តច្បាប់កូវីដ-១៩ យ៉ាងតក់ក្រហល់ ដោយមិនបានពិគ្រោះយោបល់ជាមួយសង្គមស៊ីវិល និងបានប្រកាសឱ្យប្រើច្បាប់នេះនៅថ្ងៃទី១១ ខែមីនា ឆ្នាំ២០២១ ។ ច្បាប់នេះបានផ្តល់ឱ្យរដ្ឋាភិបាលនូវអំណាច និងការសម្រេចចិត្តដ៏ទូលំទូលាយ ដែលប៉ះពាល់ដល់សិទ្ធិសង្គម សិទ្ធិនយោបាយ និងសិទ្ធិសេដ្ឋកិច្ចជាមូលដ្ឋាន ។ ច្បាប់ដែលមានលក្ខណៈរឹតត្បិតនេះ ត្រូវបានអនុវត្តតាមរយៈការអនុម័តអនុក្រឹត្យចំនួនពីរនៅមុនដំណាច់ខែមីនា ។ ភាគីពាក់ព័ន្ធជាតិ និងអន្តរជាតិបានលើកឡើងភ្លាមៗនូវការព្រួយបារម្ភពីការរំលោភបំពានដែលអាចកើតមាននៅក្នុងសេចក្តីព្រាងច្បាប់ដែលមានលក្ខណៈមិនល្អគ្រប់គ្រាន់ ដោយកំណត់យកការផ្តន្ទាទោសដាក់ពន្ធនាគារជាកាតព្វកិច្ច និងមានកម្រិតធ្ងន់ធ្ងរហួសហេតុ និងការផាកពិន័យចំពោះការរំលោភលើវិធានការរដ្ឋបាល និងប្រភេទនៃបទល្មើសដែលមិនបានសរសេរឱ្យបានច្បាស់លាស់ ។[៣] អត្ថបទជាងពាក់កណ្តាលនៃច្បាប់កូវីដ-១៩ បានចែងតែពីការផ្តន្ទាទោស រួមទាំងការផ្តន្ទាទោសដាក់ពន្ធនាគាររហូតដល់២០ឆ្នាំ ប៉ុន្តែភាសាមិនច្បាស់លាស់ក្នុងមាត្រាមួយពាក់ព័ន្ធនឹងការទទួលខុសត្រូវរបស់អាជ្ញាធរ អាចត្រូវបានប្រើប្រាស់សម្រាប់ជួយការពារមន្ត្រីក្នុងការរំលោភអំណាច ។

មួយឆ្នាំក្រោយការអនុវត្តច្បាប់នេះ ការភ័យខ្លាចទាំងនេះពិតជាកើតឡើងមែន ដោយសារច្បាប់នេះត្រូវបានគេប្រើប្រាស់តាមអំពើចិត្ត ដើម្បីគាបសង្កត់ការងាររបស់អ្នកការពារសិទ្ធិមនុស្ស និងអ្នកការពារសិទ្ធិដីធ្លី ក៏ដូចជាការរឹតត្បិតសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋក្នុងការជួបប្រជុំដោយសន្តិវិធី និងសិទ្ធិផ្សេងៗទៀត ។ កម្ពុជាមិនមែនជាប្រទេសតែមួយដែលប្រើជំងឺកូវីដ-១៩ ជាហេតុផលដើម្បីអនុម័ត

[៣] សូមមើល "ការវិភាគផ្នែកសិទ្ធិមនុស្សលើច្បាប់ស្តីពីវិធានការទប់ស្កាត់ការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ផ្សេងទៀត" ដែលចេញផ្សាយដោយ OHCHR នៅខែមេសា ឆ្នាំ២០២១ ដកស្រង់ពី៖ https://cambodia.ohchr.org/en/publications-materials/reports

ច្បាប់ថ្មីបែបគាបសង្កត់នោះទេ ប៉ុន្តែប្រទេសមួយចំនួនទៀតដូចជាប្រទេសហ្វីលីពីន និងហុងគ្រីជាដើម ក៏ជាប្រទេសដែលប្រើជំងឺកូវីដ-១៩ ជាហេតុផលដើម្បីអនុម័តច្បាប់ស្រដៀងគ្នានេះដែរ ។[៤]

ក្នុងរយៈពេលប៉ុន្មានខែបន្ទាប់ពីការប្រកាសឱ្យប្រើច្បាប់កូវីដ-១៩ កម្ពុជាបានប្រើប្រាស់ច្បាប់នេះ ដើម្បីអនុវត្តការរឹតត្បិត និងការបិទខ្ទប់ដោយបំពានចាប់ពីខែមេសាដល់ខែសីហាឆ្នាំ២០២១ ។ ការបិទខ្ទប់ទាំងនេះបានប៉ះពាល់ប្រជាពលរដ្ឋកម្ពុជារាប់សែននាក់ក្នុងស្រុកចំនួន៣០ នៅទូទាំងខេត្តចំនួន១៣ ។ តំបន់នៃការបិទខ្ទប់ត្រូវបានបែងចែកជា តំបន់លឿង តំបន់លឿងទុំ ឬតំបន់ក្រហម ដោយតំបន់ក្រហមជាតំបន់ដែលមានការរឹតត្បិតខ្លាំងបំផុត និងការហាមប្រាមស្ទើរតែទាំងស្រុងលើការធ្វើដំណើរ ដែលវិធានការនេះបានប៉ះពាល់ធ្ងន់ធ្ងរដល់ការទទួលបានអាហារ និងការថែទាំសុខភាពរបស់ប្រជាពលរដ្ឋ ។ របាយការណ៍ក្នុងឆ្នាំ២០២១របស់អគ្គលេខាធិការនៃអង្គការសហប្រជាជាតិប្រចាំក្រុមប្រឹក្សាសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ បានកត់សម្គាល់ថា យ៉ាងតិចណាស់មានប្រជាពលរដ្ឋចំនួន ៧២៩ នាក់ត្រូវបានចាប់ឬឃាត់ខ្លួនតាមច្បាប់កូវីដ-១៩ ក្នុងរយៈពេលមិនដល់ពីរខែផង គឺនៅចន្លោះពាក់កណ្ដាលខែមេសា ដល់ចុងខែឧសភា ឆ្នាំ២០២១ ដោយមានប្រជាពលរដ្ឋចំនួន១២៦ នាក់ត្រូវបានចោទប្រកាន់ចំនួន១១០នាក់ត្រូវបានបញ្ជូនទៅឃុំខ្លួនបណ្ដោះអាសន្ន និងចំនួន១៦ នាក់ត្រូវបានផ្ដន្ទាទោស ។[៥] រាជរដ្ឋាភិបាលកម្ពុជា បានបដិសេធតួលេខទាំងនេះ ។[៦]

---

[៤] Kenneth Roth, "វិធីដែលពួកផ្ដាច់ការកំពុងប្រើប្រាស់ជំងឺកូវីដ-១៩ ដើម្បីដណ្ដើមអំណាច", The New York Review of Books ចេញផ្សាយនៅថ្ងៃទី៣ ខែមេសា ឆ្នាំ២០២០ ដកស្រង់ពី៖ https://www.hrw.org/news/2020/04/03/how-authoritarians-are-exploiting-covid-19-crisis-grab-power

[៥] តួនាទី និងសមិទ្ធផលរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅក្នុងការជួយរដ្ឋាភិបាល និងប្រជាពលរដ្ឋកម្ពុជានៅក្នុងការលើកកម្ពស់ និងការពារសិទ្ធិមនុស្ស, របាយការណ៍របស់អគ្គលេខាធិការដែលដាក់ជូនក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ អ/កអ/៤៨/៤៩ នៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២១ នៅកថាខ័ណ្ឌទី ១.២៤ ។

[៦] ការកត់ត្រាសង្ខេបនៃកិច្ចប្រជុំលើកទី៣៨៥៤ កាលពីថ្ងៃទី១១ ខែមីនា ឆ្នាំ២០២២ គណៈកម្មាធិការសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ CCPR/C/SR.3854 កាលពីថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២២ កថាខណ្ឌទី២០ ដកស្រង់ពី៖ https://tbinternet.ohchr.org/_layouts/15/treatybodyexternal/Download.aspx?symbolno=CCPR%2fC%2fSR.3854&Lang=en ("ភាគច្រើននៃមនុស្សដែលបានបំពានច្បាប់នេះគឺគ្រាន់តែត្រូវបានពិន័យ ព្រមាន និងអនុញ្ញាតឱ្យត្រឡប់ទៅផ្ទះវិញ ។ មានតែ៤៤ករណីស្មើនឹងមនុស្ស១១៥នាក់ប៉ុណ្ណោះ ដែលត្រូវបានបញ្ជូនទៅតុលាការ …"), សូមមើល ម៉ៅ សុផា និងភួង វ៉ាន់ថា "កម្ពុជាត្រូវបានចាត់ថ្នាក់ទាបនៃនីតិរដ្ឋ" ដោយ Cambodianess ចេញផ្សាយថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២១ ដកស្រង់ពី៖ https://cambodianess.com/article/cambodia-ranked-low-for-rule-of-law ("ជិន ម៉ាលីន បានលើកឡើងថាជាការពិត មនុស្សប្រហែល១០០នាក់ នៃអ្នកដែលត្រូវបានឃាត់ខ្លួនជាង៧០០នាក់ ត្រូវបានបញ្ជូនទៅតុលាការ ។ ក្នុង១០០នាក់នោះ មានតែ៣០នាក់ប៉ុណ្ណោះ ដែលត្រូវបានឃុំខ្លួន ។ អ្នកផ្សេងទៀត គ្រាន់តែត្រូវបានពិន័យ និងអនុញ្ញាតឱ្យត្រឡប់ទៅផ្ទះវិញ") ។

នៅដើមឆ្នាំ២០២២ នៅពេលដែលករណីឆ្លងជំងឺកូវីដ-១៩ និងការបិទខ្ទប់បានថយចុះ គេសង្កេតឃើញកាន់តែច្បាស់ថា ច្បាប់នេះត្រូវបានប្រើប្រាស់ប្រឆាំងនឹងអ្នកការពារសិទ្ធិមនុស្ស រួមទាំងសមាជិកសហជីពចំនួនប្រាំមួយរូប ដែលត្រូវបានចាប់ខ្លួន និងចោទប្រកាន់តាមច្បាប់កូវីដ-១៩ ដោយសារការចូលរួមរបស់ពួកគេនៅក្នុងកូដកម្មអហិង្សាជាបន្តបន្ទាប់ ។ វិធានការចត្តាឡីស័កតាមច្បាប់នេះត្រូវបានប្រើប្រាស់ដោយរំលោភបំពានលើកម្មករ ដែលធ្វើកូដកម្មនៅរាជធានីភ្នំពេញនៅក្នុងខែកុម្ភៈ និងខែមីនា ឆ្នាំ២០២២ និងប្រើប្រាស់ប្រឆាំងនឹងអ្នកតវ៉ាសិទ្ធិដីធ្លីនៅខេត្តស្វាយរៀងនៅក្នុងខែសីហា ឆ្នាំ២០២១ ។ ក្នុងពេលដ៏ឆាប់រហ័ស ច្បាប់កូវីដ-១៩ ជាញឹកញាប់ត្រូវបានគេប្រើជាឧបករណ៍ថ្មីមួយនៅក្នុងក្របខណ្ឌច្បាប់ជាតិ ដែលជាអាវុធប្រឆាំងនឹងអ្នកការពារសិទ្ធិមនុស្ស អ្នកការពារសិទ្ធិដីធ្លី និងសំឡេងអ្នករិះគន់ ។ ការរំលោភអំណាចដែលបានចងក្រងជាឯកសារនេះ បានបង្ហាញយ៉ាងច្បាស់ថាការធ្វើសេចក្តីព្រាង និងការអនុម័តច្បាប់ថ្មីនៅក្នុងប្រព័ន្ធដឹកនាំរដ្ឋដែលមកពីគណបក្សតែមួយ គឺមិនបានធានា និងលើកកម្ពស់សិទ្ធិប្រជាពលរដ្ឋ ។ ផ្ទុយទៅវិញ ច្បាប់ទាំងនោះនៅតែពង្រីកអំណាច និងសិទ្ធិសម្រេច ដើម្បីទប់ទល់នឹងបុគ្គលដែលគេកំណត់ថាជាអ្នកប្រឆាំង និងអ្នករិះគន់រដ្ឋាភិបាល និងដើម្បីពង្រឹងបក្សកាន់អំណាចបន្ថែមទៀតតែប៉ុណ្ណោះ ។

ការវិភាគនេះត្រូវបានរៀបចំឡើងដោយផ្អែកលើការបកប្រែភាសាអង់គ្លេសក្រៅផ្លូវការ និងឯកសារផ្លូវការជាភាសាខ្មែរនៃច្បាប់កូវីដ-១៩ និងអនុក្រឹត្យពាក់ព័ន្ធ ។ ច្បាប់បកប្រែជាភាសាអង់គ្លេសក្រៅផ្លូវការ ច្បាប់ដើមជាភាសាខ្មែរ និងអនុក្រឹត្យអាចរកបាននៅទីនេះ ដើម្បីជាឯកសារយោង ។ ព័ត៌មានបន្ថែមត្រូវបានទទួលតាមរយៈសកម្មភាពត្រួតពិនិត្យ ដែលបានធ្វើឡើងក្នុងអាណត្តិរបស់អង្គការលីកាដូ ។ អង្គការលីកាដូបានបន្តការឃ្លាំមើលសិទ្ធិមនុស្ស និងផ្តល់សេវាសំខាន់ៗ រួមមានសេវាសង្គម និងជំនួយផ្នែកច្បាប់ ក្នុងពេលមានជំងឺរាតត្បាតនេះ ។ សកម្មភាពឃ្លាំមើលទាំងនេះត្រូវបានធ្វើឡើងដោយពិចារណាលើច្បាប់ដែលពាក់ព័ន្ធ និងសេចក្តីណែនាំដែលកំពុងដាក់ចេញ ជាមួយនឹងការគោរពវិធានការសុខាភិបាលយ៉ាងតឹងរ៉ឹង ដូចជាការពាក់ឧបករណ៍ការពារសុវត្ថិភាពផ្ទាល់ខ្លួនជាដើម ។ នៅពេលដែលករណីឆ្លងជំងឺកូវីដ-១៩ និងវិធានការរដ្ឋបាលកើនឡើងនៅក្នុងប្រទេសកម្ពុជា អង្គការលីកាដូបានតាមដានការវិវត្ត និងការរំលោភសិទ្ធិមនុស្ស ហើយបានចងក្រងរបាយការណ៍សង្ខេបប្រចាំថ្ងៃ ។ ដោយសារល្បឿននៃការវិវត្តនៃករណីឆ្លងមានការយឺតយ៉ាវ ការសង្ខេបអំពីជំងឺកូវីដ-១៩ ត្រូវបានចេញជារៀងរាល់សប្តាហ៍វិញ និងបន្ទាប់មកជាប្រចាំខែ ។ ច្បាប់ជាតិ ច្បាប់និងបទដ្ឋានអន្តរជាតិដែលពាក់ព័ន្ធ និងការរាយការណ៍ពីអង្គការក្នុងស្រុក និងអន្តរជាតិក៏ត្រូវបានពិនិត្យផងដែរ ។ វិសាលភាពនៃផលប៉ះពាល់ដែលបានសិក្សា គឺគិតចាប់ពីថ្ងៃទី១១ ខែមីនា ឆ្នាំ២០២១ រហូតដល់ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២២ ។

## ទិដ្ឋភាពទូទៅនៃច្បាប់ និងអនុក្រឹត្យស្តីពីជំងឺកូវីដ-១៩

សេចក្តីព្រាងច្បាប់ស្តីពីជំងឺកូវីដ-១៩ ត្រូវបានបង្ហាញនៅថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២១ និងអនុម័តដោយរដ្ឋសភានៅថ្ងៃទី៥ ខែមីនា ឆ្នាំ២០២១ នាសម័យប្រជុំរដ្ឋសភាជាវិសាមញ្ញ នីតិកាលទី៦ ។ ច្បាប់កូវីដ-១៩ ត្រូវបានពិនិត្យ និងអនុម័តដោយព្រឹទ្ធសភានៅថ្ងៃទី១១ ខែមីនា ឆ្នាំ២០២១ នាសម័យប្រជុំជាវិសាមញ្ញ នីតិកាលទី៤ ។ ច្បាប់នេះត្រូវបានចុះហត្ថលេខាជាផ្លូវការដោយប្រមុខរដ្ឋស្តីទីនៅថ្ងៃទី១១ ខែមីនា ឆ្នាំ២០២១ ហើយចូលជាធរមានភ្លាមៗដោយមិនមានការពិគ្រោះយោបល់ជាមួយសង្គមស៊ីវិលឡើយ ។[៧]

នៅថ្ងៃបន្ទាប់ គឺនៅថ្ងៃទី១២ ខែមីនា ឆ្នាំ២០២១ សម្តេចនាយករដ្ឋមន្ត្រី បានចុះហត្ថលេខាលើអនុក្រឹត្យស្តីពីវិធានការសុខាភិបាល ដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ផ្សេងទៀត (អនុក្រឹត្យស្តីពីវិធានការសុខាភិបាល) កំណត់បទប្បញ្ញត្តិដើម្បីអនុវត្តមាត្រា៣នៃច្បាប់កូវីដ-១៩ ។[៨] សម្តេចក៏បានចុះហត្ថលេខាលើអនុក្រឹត្យស្តីពីវិធានការរដ្ឋបាលសម្រាប់ការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត (អនុក្រឹត្យស្តីពីវិធានការរដ្ឋបាល) នៅថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១ ដែលបានប្រកាសឱ្យប្រើបទប្បញ្ញត្តិបន្ថែមទៀតសម្រាប់ការអនុវត្តមាត្រា៤ នៃច្បាប់នេះ ។[៩]

បញ្ហា និងការរំលោភបំពានជាច្រើន ដែលបានចងក្រងជាឯកសារនៅក្នុងការវិភាគនេះ ត្រូវបានលើកឡើងដោយសង្គមស៊ីវិល និងអង្គការសហប្រជាជាតិក្នុងសេចក្តីថ្លែងការណ៍ជាសាធារណៈ និងការទំនាក់ទំនងទៅកាន់រដ្ឋាភិបាលកម្ពុជា ។[១០] មួយឆ្នាំបន្ទាប់ពីការប្រកាសឱ្យប្រើច្បាប់នេះ គណៈកម្មាធិការ

---

[៧] សូមមើល ឧ. "ការទំនាក់ទំនងទៅកាន់រាជរដ្ឋាភិបាលកម្ពុជា ពីអ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា អ្នករាយការណ៍ពិសេសស្តីពីសិទ្ធិសេរីភាពក្នុងការជួបប្រជុំដោយសន្តិវិធី និងសិទ្ធិក្នុងការបង្កើតសមាគម និងអ្នករាយការណ៍ពិសេសស្តីពីឯករាជ្យភាពនៃចៅក្រម និងមេធាវី" (ទំនាក់ទំនងអ្នករាយការណ៍ពិសេស), OHCHR, OL KHM 4/2021 ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១ ដកស្រង់ពីៈ https://spcommreports.ohchr.org/TMResultsBase/DownLoadPublicCommunicationFile?gId=26266

[៨] អនុក្រឹត្យស្តីពីវិធានការសុខាភិបាល ដើម្បីទប់ស្កាត់ការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ផ្សេងទៀត (អនុក្រឹត្យស្តីពីវិធានការសុខាភិបាល) លេខ ៣៧ អនក្រ/បក (១២ មីនា ២០២១) សូមមើលមាត្រា ៣ ច្បាប់កូវីដ-១៩ (វិធានការសុខាភិបាល) ។

[៩] អនុក្រឹត្យស្តីពីវិធានការសុខភាព ដើម្បីទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងដ៏កាចសាហាវផ្សេងទៀត (អនុក្រឹត្យស្តីពីវិធានការសុខភាព) លេខ ៣៧ អនក្រ/បក (១២ មីនា ២០២១) សូមមើលមាត្រា ៣ ច្បាប់កូវីដ១៩ (វិធានការសុខាភិបាល) ។

[១០] សូមមើល ឧ. "ការវិភាគផ្នែកសិទ្ធិមនុស្សនៃច្បាប់ស្តីពីវិធានការបង្ការប្រឆាំងនឹងការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត", OHCHR, ខែមេសា ឆ្នាំ២០២១ ។

សិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិបានលើកឡើងពីការព្រួយបារម្ភថាច្បាប់កូវីដ-១៩ កំពុងត្រូវបានអនុវត្តក្នុងលក្ខណៈរើសអើង និងចោទជាសំណួរថាតើរដ្ឋាភិបាលគួរធ្វើវិសោធនកម្ម ឬលុបចោលច្បាប់នេះតែម្តង ។[១១]

## ក. គោលបំណង និងវិសាលភាពមិនច្បាស់លាស់

គោលបំណងនៃច្បាប់កូវីដ-១៩ អនុក្រឹត្យស្តីពីវិធានការសុខាភិបាល និងអនុក្រឹត្យស្តីពីវិធានការរដ្ឋបាល ត្រូវបានកំណត់យ៉ាងទូលំទូលាយថាជា "ការការពារអាយុជីវិតប្រជាពលរដ្ឋ សុខភាពសាធារណៈ និងសណ្តាប់ធ្នាប់សាធារណៈ" និងកាត់បន្ថយ "ផលប៉ះពាល់" លើវិស័យសង្គម និងសេដ្ឋកិច្ចរបស់កម្ពុជា ។[១២] គោលបំណងដែលបានកំណត់នៅក្នុងច្បាប់ណាមួយ គួរតែមានបញ្ជាក់យ៉ាងច្បាស់ពីចេតនារបស់ស្ថាប័ននីតិប្បញ្ញត្តិ ដើម្បីណែនាំដល់ការអនុវត្តច្បាប់នោះឱ្យបានត្រឹមត្រូវ ។ គោលបំណងនៃការការពារអាយុជីវិតប្រជាជន និងសុខភាពសាធារណៈ មានលក្ខណៈទូលំទូលាយ ប៉ុន្តែដើម្បីឱ្យគោលបំណងទាំងពីរ មានលក្ខណៈគ្រប់គ្រាន់ ទាល់តែមានការបញ្ជាក់ឱ្យបានច្បាស់លាស់ ឬការណែនាំបន្ថែមចំពោះកាតព្វកិច្ចរបស់រដ្ឋាភិបាលក្នុងការធានាសិទ្ធិរបស់ប្រជាពលរដ្ឋ ។[១៣] ទោះជាយ៉ាងនេះក្តី អនុក្រឹត្យជាបន្តបន្ទាប់ស្តីពីវិធានការសុខាភិបាល និងវិធានការរដ្ឋបាលមិនបានផ្តល់ការណែនាំច្បាស់លាស់ចំពោះការអនុវត្តច្បាប់នេះទេ ប៉ុន្តែបែរជាបញ្ជាក់ឡើងវិញនូវអំណាចមិនច្បាស់លាស់យ៉ាងទូលំទូលាយដែលបង្ហាញពីហានិភ័យចំពោះការអនុវត្តច្បាប់ដោយមិនត្រឹមត្រូវ ។ ការអនុវត្តដោយរើសអើង បានរំលោភលើសិទ្ធិមនុស្សរបស់ពលរដ្ឋ ដែលធានាដោយរដ្ឋធម្មនុញ្ញ ក៏ដូចជាការធានាថាប្រជាពលរដ្ឋទាំងអស់មានភាពស្មើគ្នាចំពោះមុខច្បាប់ ។[១៤]

ជាងនេះទៅទៀត ការបន្ថែម "សណ្តាប់ធ្នាប់សាធារណៈ" និង "ផលប៉ះពាល់" លើវិស័យសង្គម និងសេដ្ឋកិច្ច ទៅនឹងគោលបំណងនៃច្បាប់គឺមិនចាំបាច់ និងមានលក្ខណៈទូលំទូលាយ និងមិនច្បាស់លាស់ដែលពិបាកនឹងទទួលយកបាន ។ ពាក្យនេះគ្រាន់តែបង្កើតឱកាសផ្លូវច្បាប់ និងហេតុផលសម្រាប់គណបក្សកាន់អំណាចក្នុងការរឹតត្បិតសេរីភាពរបស់បុគ្គលណាម្នាក់ ដែលគេយល់ថាជាគូបដិបក្ខ ឬជាអ្នករិះគន់រដ្ឋាភិបាល ដែលការណ៍នេះផ្ទុយនឹងគោលការណ៍ជាសាកល ដោយស្មើភាព និងយុត្តិធម៌ដែលជាមូលដ្ឋាននៃសិទ្ធិមនុស្ស ។ ដូច្នេះវាបង្ហាញឱ្យឃើញច្បាស់តាំងពីមាត្រាដំបូងនៃច្បាប់ និង

[១១] "ក្នុងកិច្ចសន្ទនាជាមួយកម្ពុជា៖ អ្នកជំនាញនៃគណៈកម្មាធិការសិទ្ធិមនុស្សសួរអំពីសេរីភាពក្នុងការបញ្ចេញមតិ និងលើកបញ្ហាទាក់ទងនឹងវិធានការបង្ការជំងឺកូវីដ-១៩", OHCHR ថ្ងៃទី១១ ខែមីនា ឆ្នាំ២០២២ ដកស្រង់ពី៖ https://www.ohchr.org/en/press-releases/2022/03/dialogue-cambodia-experts-human-rights-committee-ask-about-freedom

[១២] មាត្រា១ នៃច្បាប់កូវីដ-១៩ មាត្រា១ នៃអនុក្រឹត្យស្តីពីវិធានការសុខភាព មាត្រា១ អនុក្រឹត្យស្តីពីវិធានការរដ្ឋបាល

[១៣] មាត្រា៣១ ៣២ ៣៨ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា (១៩៩៣)

[១៤] មាត្រា៣១ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

អនុក្រឹត្យស្តីពីជំងឺកូវីដ-១៩ ថាច្បាប់នេះអាចត្រូវគេបំពានដោយប្រើអំណាចយ៉ាងទូលំទូលាយនៅក្នុងការរឹតត្បិតសិទ្ធិមនុស្ស ជាជាងជួយរដ្ឋាភិបាលក្នុងការបំពេញកាតព្វកិច្ចដើម្បីការពារសិទ្ធិប្រជាពលរដ្ឋ ។

វិសាលភាពនៃច្បាប់កូវីដ-១៩ និងអនុក្រឹត្យ ក៏គ្មានដែនកំណត់ច្បាស់លាស់ដែរ ។ ច្បាប់ និងអនុក្រឹត្យស្តីពីការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និង "ជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរ" ផ្សេងទៀត ។[១៥] មិនមានផ្នែកកំណត់និយមន័យនៅក្នុងច្បាប់ ឬអនុក្រឹត្យស្តីពីកូវីដ-១៩ នេះទេ ដូច្នេះក៏គ្មានការណែនាំណាមួយដើម្បីកំណត់ថាតើអ្វីទៅជាជំងឺឆ្លងកាចសាហាវ ប្រកបដោយគ្រោះថ្នាក់ និងធ្ងន់ធ្ងរនោះដែរ ។ ការអានដោយសាមញ្ញនៃពាក្យពេចន៍ទាំងនេះបង្ហាញពីវិសាលភាពទូលំទូលាយ ដែលពុំមានន័យសំខាន់ និងជាហានិភ័យដែលច្បាប់នេះអាចត្រូវគេយកមកប្រើនៅក្នុងការឆ្លើយតបទៅនឹងស្ទើរតែគ្រប់ជំងឺឆ្លងទាំងអស់ ជាពិសេសនៅពេលអានដោយភ្ជាប់ជាមួយគោលបំណងទូទៅនៃច្បាប់នេះ ។ ការទទួលខុសត្រូវក្នុងការសម្រេចចិត្ត និងពេលវេលាដែលច្បាប់នេះអាចប្រើប្រាស់បាន ជាបន្ទុកទាំងស្រុងរបស់ក្រសួងសុខាភិបាល ។[១៦] ការប្រមូលផ្តុំអំណាចនៅក្នុងស្ថាប័នតែមួយ ដែលត្រូវបានផ្តល់សិទ្ធិអំណាចដាច់ខាតក្នុងការអនុវត្តវិធានការដ៏ទូលំទូលាយ ដែលអាចនឹងប៉ះពាល់ដល់សិទ្ធិមនុស្សយ៉ាងធ្ងន់ធ្ងរ ដោយសារតែគ្មានការណែនាំ ឬការតម្រូវឱ្យមានការពិគ្រោះយោបល់ជាមួយអាជ្ញាធរ ឬភាគីពាក់ព័ន្ធផ្សេងទៀត នឹងបង្កឱ្យមានការរំខាន និងការរំលោភបំពានដែលអាចកើតមាន ។

ជាចុងក្រោយ ពុំមានការកំណត់ពេលវេលា ឬការតម្រូវឱ្យមានការត្រួតពិនិត្យឡើងវិញតាមពេលវេលាកំណត់ថាតើវិធានការសុខាភិបាលដ៏ទូលំទូលាយនេះ គឺពិតជាមានភាពចាំបាច់ និងត្រូវបានអនុញ្ញាតទៅតាមច្បាប់នេះពិតប្រាកដមែនឬយ៉ាងណា ។ វិធានការរដ្ឋបាលត្រូវបានកំណត់ ជាដំបូង ក្នុងរយៈពេលមិនឱ្យលើសពីពីរសប្តាហ៍ ។ ប៉ុន្តែដោយសាររយៈពេលនេះអាចត្រូវបានបន្តក្នុងរយៈពេលមិនកំណត់ និងក្នុងចំនួនដងមិនច្បាស់លាស់ ដូច្នេះវាមានប្រសិទ្ធភាពគ្មានដែនកំណត់ ។[១៧] ដោយសារជំងឺកូវីដ-១៩ ទំនងជាមិនរលាយបាត់ទាំងស្រុងនោះទេ អំណាចដ៏សម្បើម និងមិនច្បាស់លាស់នៅក្នុងច្បាប់កូវីដ-១៩ អាចត្រូវបានប្រតិបត្តិនៅពេលណាក៏បាន ដោយគ្មានកំណត់ ដោយតួអង្គជាច្រើនរបស់រដ្ឋាភិបាល ។

---

[១៥] មាត្រា ២ និង១៥ នៃច្បាប់កូវីដ១៩ មាត្រា ២ និង៣២ នៃអនុក្រឹត្យស្តីពីវិធានការសុខាភិបាល មាត្រា២ និង២០ នៃអនុក្រឹត្យស្តីពីវិធានការរដ្ឋបាល

[១៦] មាត្រា២ និង១៥ នៃច្បាប់កូវីដ-១៩

[១៧] មាត្រា ១២–១៣ នៃអនុក្រឹត្យស្តីពីវិធានការរដ្ឋបាល

## ខ. អំណាច និងសិទ្ធសម្រេចចិត្តដ៏ទូលំទូលាយ

អំណាចដ៏ទូលំទំលាយដែលផ្តល់ឱ្យរដ្ឋាភិបាលកម្ពុជាក្នុងមាត្រា៣ និងមាត្រា៤ នៃច្បាប់កូវីដ-១៩ ត្រូវបានសរសេរឡើងដោយប្រើភាសាមិនច្បាស់ មិនមានលក្ខណៈគ្រប់គ្រាន់ និងគ្មានដែនកំណត់ច្បាស់លាស់ ។ សកម្មភាពដែលត្រូវអនុញ្ញាតរួមមាន៖

- ចត្តាឡីស័ក[១៨]
- ការដាក់ឱ្យនៅដាច់ដោយឡែកដើម្បីទទួលការព្យាបាល[១៩]
- ការរឹតត្បិត ឬការហាមឃាត់ការធ្វើដំណើរ[២០]
- ការរឹតត្បិត ឬការហាមឃាត់ការជួបប្រជុំ និងការប្រមូលផ្តុំមនុស្ស ដែលសកម្មភាពនេះ "អាច" បណ្តាលឱ្យមានការឆ្លងរាលដាលនៃជំងឺកូវីដ-១៩[២១]
- ការហាមឃាត់ ឬការកម្រិតការធ្វើសកម្មភាពការងារ ឬមុខរបរដែលជា "ហានិភ័យ" ឬជាប្រភពនៃការឆ្លងរាលដាលនៃជំងឺកូវីដ-១៩[២២]
- ការបិទខ្ទប់តំបន់ ឬទីកន្លែងមួយចំនួនដែលមានការឆ្លងរាលដាលនៃជំងឺកូវីដ-១៩[២៣]
- វិធានការសុខាភិបាល និងវិធានការរដ្ឋបាល "ផ្សេងទៀត" "ដែលមានភាពចាំបាច់ ដើម្បីឆ្លើយតបនឹងការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩"[២៤]

វិធានការណាមួយក្នុងចំណោមវិធានការទាំងនេះ មានហានិភ័យខ្ពស់ចំពោះការកម្រិតសិទ្ធិមនុស្សជាមូលដ្ឋាន រួមទាំងសិទ្ធិក្នុងការធ្វើដំណើរ សេរីភាពក្នុងការជួបប្រជុំដោយសន្តិវិធី សេរីភាពក្នុងការបង្កើតសមាគម និងសេរីភាពក្នុងការបញ្ចេញមតិ ។ ការរឹតត្បិតណាមួយលើសិទ្ធិជាមូលដ្ឋានទាំងនេះត្រូវតែស្ថិតក្នុងភាពចាំបាច់នៅក្នុងសង្គមប្រជាធិបតេយ្យ ដើម្បីធានាសម្រេចបាននូវគោលបំណង

---

[១៨] មាត្រា ៣ នៃច្បាប់កូវីដ-១៩

[១៩] មាត្រា ៣ នៃច្បាប់កូវីដ-១៩

[២០] មាត្រា ៤ នៃច្បាប់កូវីដ-១៩

[២១] មាត្រា ៤ នៃច្បាប់កូវីដ-១៩

[២២] មាត្រា ៤ នៃច្បាប់កូវីដ-១៩

[២៣] មាត្រា ៤ នៃច្បាប់កូវីដ-១៩

[២៤] មាត្រា ៣ និង ៤ នៃច្បាប់កូវីដ-១៩

ស្របច្បាប់ ហើយត្រូវតែសមាមាត្រទៅនឹងគោលបំណងនោះផងដែរ ។[២៥] ខណៈពេលដែលសុខភាពសាធារណៈគឺជាមូលដ្ឋានស្របច្បាប់សម្រាប់ការរឹតត្បិត រាល់ការរឹតត្បិតណាមួយត្រូវតែមានភាពចាំបាច់ សមាមាត្រ និងសមស្របជាមួយនឹងសិទ្ធិផ្សេងទៀតដែលមានចែងក្នុងច្បាប់អន្តរជាតិ ។[២៦] ការរឹតត្បិតគួរតែត្រូវបានចាត់ទុកថាគ្រាន់តែជាវិធានការនៃមធ្យោបាយចុងក្រោយបង្អស់ប៉ុណ្ណោះ ។ គេត្រូវតែប្រើមធ្យោបាយដែលមិនមានលក្ខណៈរឹតត្បិតខ្លាំង ដែលស្របទៅតាមគោលបំណងផ្លូវច្បាប់ ។[២៧]

អនុក្រឹត្យស្តីពីវិធានការសុខាភិបាលបែងចែកប្រភេទ និងការណែនាំមួយចំនួនលើវិធានការសុខាភិបាលដែលត្រូវដាក់ចេញ ដូចជាការធ្វើតេស្តរកមេរោគកូវីដ-១៩ ការធ្វើចត្តាឡីស័ក និងការដាក់ឱ្យនៅដាច់ដោយឡែក ហើយអនុក្រឹត្យស្តីពីវិធានការរដ្ឋបាលបានបង្កើតករណីលើកលែងផ្សេងៗដើម្បីដាក់ចេញនូវការរឹតត្បិតទាំងនេះ ។ ជាក់ស្តែង អនុក្រឹត្យស្តីពីវិធានការរដ្ឋបាល គឺផ្ទុយពីបទដ្ឋានច្បាប់សម្រាប់ការរឹតត្បិតសិទ្ធិ ។ ជាជាងជ្រើសរើសយកការរឹតត្បិតជាមធ្យោបាយចុងក្រោយ អនុក្រឹត្យនេះអនុញ្ញាតឱ្យមានការរឹតត្បិត និងការហាមឃាត់លើសិទ្ធិមនុស្ស ហើយបន្ទាប់មកទុកចន្លោះឱ្យមានករណីលើកលែងតិចតួច និងមិនច្បាស់លាស់ទៅលើការរឹតត្បិតទាំងនោះ ដែលអាចនាំឱ្យមានការអនុវត្តដោយរំលោភបំពាន ។ ដូច្នេះ វាមានហានិភ័យខ្ពស់ចំពោះការរំលោភបំពាន ហើយលទ្ធផលនៃការរឹតត្បិតនេះនឹងរំលោភបំពានដោយមិនត្រឹមត្រូវលើសិទ្ធិរបស់ប្រជាពលរដ្ឋ និងមិនមានភាពចាំបាច់ ឬសមស្រប ។

គោលការណ៍ជាមូលដ្ឋាននៃច្បាប់ គឺត្រូវតែតាក់តែងឱ្យច្បាស់លាស់ ដើម្បីជូនដំណឹងដល់សាធារណជនទាក់ទងនឹងសិទ្ធិ និងការហាមឃាត់ផ្សេងៗ ។ នៅក្នុងច្បាប់ ឬអនុក្រឹត្យស្តីពីជំងឺកូវីដ-១៩ នេះ គ្មានផ្នែកកំណត់និយមន័យនោះទេ ។ ពាក្យ និងឃ្លាសំខាន់ៗនៅតែមិនត្រូវបានកំណត់ឱ្យបានច្បាស់លាស់ ដូចជា "អត្ថប្រយោជន៍" "ភាពបន្ទាន់ និងភាពចាំបាច់" "អំពើគេចវេះពីការធ្វើចត្តាឡីស័ក"

---

[២៥] សូមមើល ឧ. សេចក្តីអធិប្បាយទូទៅលេខ៣៧ ស្តីពីសិទ្ធិក្នុងការជួបប្រជុំដោយសន្តិវិធី (មាត្រា ២១) (សេចក្តីអធិប្បាយទូទៅលេខ ៣៧) នៅកថាខណ្ឌទី៣៦, គណៈកម្មាធិការសិទ្ធិមនុស្ស CCPR/C/GC/37 ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២០ ។

[២៦] មាត្រា ១២(៣) មាត្រា១៩(៣) មាត្រា២១(២) កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR) ឆ្នាំ ១៩៧៦ ។ ប្រទេសកម្ពុជាបានចុះហត្ថលេខាលើ ICCPR ក្នុងឆ្នាំ១៩៨០ និងបានផ្តល់សច្ចាប័នលើសន្ធិសញ្ញានេះ នៅថ្ងៃទី២៦ ខែឧសភា ឆ្នាំ១៩៩២ ។

[២៧] សេចក្តីអធិប្បាយទូទៅលេខ៣៧ នៅកថាខណ្ឌទី ៣៧, សេចក្តីអធិប្បាយទូទៅលេខ៣៤ ស្តីពីសេរីភាពនៃការបញ្ចេញមតិ និងការយល់ឃើញ (មាត្រា ១៩) (សេចក្តីអធិប្បាយទូទៅលេខ ៣៤) នៅកថាខណ្ឌទី៦, គណៈកម្មាធិការសិទ្ធិមនុស្ស, CCPR/C/GC/34, ថ្ងៃទី១២ ខែកញ្ញា២០២១, សេចក្តីអធិប្បាយទូទៅលេខ២៧ ស្តីពីសេរីភាពនៃការធ្វើដំណើរ (មាត្រា ១២) (សេចក្តីអធិប្បាយទូទៅលេខ ២៧) នៅកថាខណ្ឌទី១៣-១៦, គណៈកម្មាធិការសិទ្ធិមនុស្ស, CCPR/C/21/Rev.1/Add.9, ថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ។

"ការទទួលការព្យាបាលជាកាតព្វកិច្ច" និង "ផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរលើសុខភាពសាធារណៈ" ។[២៨] ពាក្យ និងឃ្លាទាំងនេះ នៅក្នុងអត្ថន័យធម្មតាគឺមានភាពស្រពិចស្រពិល ដែលមិនមានន័យច្បាស់លាស់ ឬខ្វះការឯកភាពជាទូទៅ ឬអត្ថន័យដែលពាក់ព័ន្ធណាមួយ ដើម្បីណែនាំដល់ការបកស្រាយ ។ ខណៈពេលដែលការបកប្រែភាសាអង់គ្លេសក្រៅផ្លូវការត្រូវបានប្រើជាមូលដ្ឋានសម្រាប់ការវិភាគនេះ ការរិះគន់ក៏ពិតដូចគ្នាចំពោះច្បាប់ផ្លូវការជាភាសាខ្មែរ ។ លក្ខខណ្ឌជាច្រើនទាំងនេះមានសារៈសំខាន់ណាស់ នៅក្នុងការកំណត់ថាតើការរំលោភបំពានច្បាប់បានកើតឡើងឬអត់ ហើយការបកស្រាយខុសគ្នាអាចបង្កឱ្យមានការដាក់ទណ្ឌកម្មធ្ងន់ធ្ងរដូចជា ការជាប់ពន្ធនាគារ ជាដើម ។ នេះជាហានិភ័យនៃភាពមិនស៊ីសង្វាក់គ្នា និងភាពមិនអាចទាយទុកជាមុនបានថាតើនៅក្នុងលក្ខខណ្ឌ និងមធ្យោបាយបែបណាដែលវិធានការសុខាភិបាល និងវិធានការរដ្ឋបាលអាចត្រូវបានអនុវត្ត ។ ការជូនដំណឹងមិនគ្រប់ជ្រុងជ្រោយដល់សាធារណជន និងលទ្ធភាពនៃការអនុវត្តដោយរំលោភបំពានក្នុងការចោទប្រកាន់ព្រហ្មទណ្ឌប្រឆាំងនឹងបុគ្គលដែលត្រូវចោទ ។

## គ. កង្វះដែនកំណត់ប្រកបដោយប្រសិទ្ធភាព ឬការត្រួតពិនិត្យ

អំណាចដ៏ទូលំទូលាយ និងប្រកបដោយឆន្ទានុសិទ្ធិដែលត្រូវបានអនុញ្ញាតនៅក្នុងច្បាប់កូវីដ-១៩ អាចត្រូវបានប្រគល់ទៅឱ្យតួអង្គផ្សេងៗក្នុងរដ្ឋាភិបាល និងអាជ្ញាធរនៅក្នុងករណីដែលមិនបានកំណត់ថាជាករណី "បន្ទាន់ និងមានភាពចាំបាច់" ។ ក្រសួងសុខាភិបាល ដូចដែលបានកត់សម្គាល់ខាងលើ មានសិទ្ធិអំណាចផ្តាច់មុខក្នុងការកំណត់នូវជំងឺផ្សេងៗដែលត្រូវការច្បាប់ ក៏អាចផ្តល់សិទ្ធិអំណាចឱ្យអាជ្ញាធរក្នុងការដាក់ចេញវិធានការសុខាភិបាលផ្សេងទៀត បន្ថែមពីលើវិធានការមិនច្បាស់លាស់ ដែលមានចែងនៅក្នុងច្បាប់រួចហើយ ។[២៩] "ក្រសួង ស្ថាប័ន ឬអាជ្ញាធរមានសមត្ថកិច្ច" ដែលមិនបានបញ្ជាក់ច្បាស់លាស់ អាចត្រូវបានផ្តល់ការសម្រេចចិត្តក្នុងការអនុវត្តវិធានការរដ្ឋបាលដែលអាចមានផលប៉ះពាល់ដល់ប្រជាពលរដ្ឋជាច្រើននាក់ ។[៣០]

អនុក្រឹត្យស្តីពីវិធានការសុខាភិបាល បញ្ជាក់យ៉ាងច្បាស់ថា ក្រសួងសុខាភិបាលអាចចេញសេចក្តីណែនាំលម្អិតអំពីវិធានការសុខាភិបាល ដែលអាចលើកកម្ពស់ភាពស៊ីសង្វាក់គ្នាក្នុងការអនុវត្តច្បាប់ ។[៣១] ទោះជាយ៉ាងនេះក្តី អនុក្រឹត្យស្តីពីវិធានការរដ្ឋបាលមិនមានដែនកំណត់ច្បាស់លាស់ ប៉ុន្តែបានផ្តល់សិទ្ធិអំណាចក្នុងការសម្រេចចិត្តដ៏ទូលំទូលាយដល់គណៈអភិបាលរាជធានី-ខេត្ត ដើម្បីចាត់វិធានការ និងអនុវត្តវិធានការរដ្ឋបាលទាំងស្រុងនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន "ទីកន្លែងដែលមានការ

---

[២៨] មើល ឧ. មាត្រា១០ នៃច្បាប់កូវីដ-១៩

[២៩] មាត្រា៣ នៃច្បាប់កូវីដ-១៩

[៣០] មាត្រា៤ នៃច្បាប់កូវីដ-១៩

[៣១] មាត្រា១៧ នៃអនុក្រឹត្យស្តីពីវិធានការសុខាភិបាល

ឆ្លងរាលដាលនៃមេរោគកូវីដ-១៩” ។[៣២] មាត្រា ១១ មាត្រា១២ និងមាត្រា១៣ នៃអនុក្រឹត្យស្តីពីវិធានការរដ្ឋបាល បញ្ជាក់យ៉ាងច្បាស់ថា គណៈអភិបាលរាជធានី ខេត្ត មានសិទ្ធិអំណាចពេញលេញក្នុងការបកស្រាយអំណាចផ្លូវច្បាប់ និងរៀបចំយន្តការចាំបាច់សម្រាប់ត្រួតពិនិត្យ ឃ្លាំមើល ណែនាំ និងអនុវត្ត ឬបន្ធូរបន្ថយវិធានការរដ្ឋបាល រួមទាំងការដាក់ចេញវិធានការផ្សេងទៀត ដែលចាត់ទុកថាជាកិច្ចការបន្ទាន់ និងមានភាពចាំបាច់ ដើម្បីគ្រប់គ្រងការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ។

អំណាច និងសិទ្ធិសម្រេចចិត្តដ៏ទូលំទូលាយនេះ កាន់តែចោទជាការក្តីបារម្ភខ្លាំងឡើង នៅពេលគេពិនិត្យទៅលើមាត្រា១២ នៃច្បាប់កូវីដ-១៩ និងមាត្រា១៧ នៃអនុក្រឹត្យស្តីពីវិធានការរដ្ឋបាល ដែលបានចែងថា អាជ្ញាធរមានសមត្ថកិច្ចអាចមិនទទួលខុសត្រូវចំពោះការប្រើប្រាស់អំណាចរបស់ខ្លួនដោយមិនត្រឹមត្រូវ ដែល “បង្កឱ្យមានការរំលោភបំពានដល់សិទ្ធិ និងសេរីភាពរបស់បុគ្គល បូរណភាពរាងកាយ ឬបណ្តាលឱ្យខូចខាតដល់ទ្រព្យសម្បត្តិ” នោះឡើយ លុះត្រាតែទង្វើនោះ “ផ្ទុយទៅនឹងគោលបំណងនៃច្បាប់នេះ” ។ ដោយមើលឃើញពីគោលបំណងទូទៅដែលមិនច្បាស់លាស់ និងមានភាពទូលំទូលាយនៃច្បាប់ និងអនុក្រឹត្យបែបនេះ បទប្បញ្ញត្តិជាធរមានអាចនឹងផ្តល់នូវអភ័យឯកសិទ្ធិដល់អាជ្ញាធរចំពោះការរំលោភអំណាច និងការរំលោភលើសិទ្ធិជាមូលដ្ឋាន ។

## ឃ.ការពិន័យធ្ងន់ធ្ងរហួសហេតុ

ជាងពាក់កណ្តាលនៃអត្ថបទច្បាប់កូវីដ-១៩ គឺផ្តោតលើការរៀបរាប់លម្អិតអំពី "ការដាក់ទណ្ឌកម្ម" ចំពោះការបំពាន ដែលភាគច្រើនជាបទឧក្រិដ្ឋ (ឧទាហរណ៍ការដាក់ពន្ធនាគារ និងការពិន័យជាប្រាក់) ជាជាងការដាក់ទណ្ឌកម្មផ្នែករដ្ឋបាល (ពោលគឺការព្យួរអាជ្ញាប័ណ្ណអាជីវកម្ម ឬការបិទអាជីវកម្ម) ។ ការផ្តោតជាសំខាន់លើការដាក់ទណ្ឌកម្ម ដែលមិនសមហេតុផល នៅតែមាននៅក្នុងច្បាប់នេះ បើទោះបីជាលក្ខខណ្ឌសំខាន់ៗនៅក្នុងច្បាប់មិនត្រូវបានកំណត់ឱ្យច្បាស់លាស់ ដោយមានការណែនាំតិចតួចបំផុត ឬគ្មានការណែនាំតែម្តងចំពោះការអនុវត្តអំណាចដ៏ទូលំទូលាយ និងមិនមានការត្រួតពិនិត្យជាផ្លូវការ ឬភាពចាំបាច់នៃការរឹតត្បិតសិទ្ធិ ។ ជារួម ករណីបង្ហាញថា ច្បាប់នេះមានគោលបំណងជាឧបករណ៍ដាក់ទណ្ឌកម្ម ជាជាងមធ្យោបាយការពារសិទ្ធិទទួលបានសុខភាពរបស់ប្រជាពលរដ្ឋ ។ អ្នកជំនាញសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិបានបង្ហាញកង្វល់ថា ការពិន័យមិនសមស្រប និងហួសហេតុដែលស្នើឡើងសម្រាប់អំពើរំលោភលើវិធានការសុខាភិបាល និងវិធានការរដ្ឋបាលគឺហាក់ដូចជាមិនមានភាពចាំបាច់ ឬសមាមាត្រនោះទេ ។ ដូច្នេះវាអាចមិនសមស្របទៅនឹងកាតព្វកិច្ចរបស់កម្ពុជាដែលត្រូវអនុវត្តតាមច្បាប់អន្តរជាតិ ។[៣៣]

---

[៣២] មាត្រា១១ នៃអនុក្រឹត្យស្តីពីវិធានការរដ្ឋបាល

[៣៣] ការទាក់ទងរបស់អ្នករាយការណ៍ពិសេស, លេខ ៣-៤

លក្ខខណ្ឌនៃការដាក់ពន្ធនាគារជាកាតព្វកិច្ចចំពោះរាល់បទល្មើសភាគច្រើន ប៉ុន្តែមិនគួរជាកាតព្វកិច្ចចំពោះបទល្មើសដែលកំណត់នៅក្នុងច្បាប់កូវីដ-១៩ និងដែលអាចមានរយៈពេលរហូតដល់ ២០ឆ្នាំ នោះទេ ។ លក្ខខណ្ឌនៃការដាក់ពន្ធនាគារលើសពី (ចាំបាច់ខ្លាំងនៅក្នុងករណីខ្លះ) ទោសទណ្ឌសម្រាប់បទល្មើសពាក់ព័ន្ធតាមក្រមព្រហ្មទណ្ឌ ។ ជាឧទាហរណ៍ បទល្មើសរារាំងមន្ត្រីរាជការសាធារណៈតាមក្រមព្រហ្មទណ្ឌ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១ ទៅ៣ ខែ ឬពី៦ ទៅ១២ ខែ ក្នុងករណីមានស្ថានទម្ងន់ទោស ។[៣៤] ការរារាំងដល់ការអនុវត្តវិធានការ តាមច្បាប់កូវីដ-១៩ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៦ ខែ ទៅ៣ ឆ្នាំ ឬពី២ ឆ្នាំ ទៅ៥ ឆ្នាំ ក្នុងករណីមានស្ថានទម្ងន់ទោស ប្រសិនបើទង្វើនោះនាំទៅដល់ការឆ្លងដល់អ្នកដទៃ ឬ “ប៉ះពាល់ធ្ងន់ធ្ងរដល់សុខភាពសាធារណៈ ។”[៣៥] ភាពមិនសមហេតុផល និងមិនសមាមាត្រនៃទោសទណ្ឌតាមច្បាប់កូវីដ-១៩ ត្រូវបានបង្ហាញក្នុងសំណុំរឿងមួយ ដែលយុវជន ៤នាក់ នៅខេត្តតាកែវ ត្រូវបានគេរកឃើញថា មានពិរុទ្ធពីបទរំលោភលើវិធានការរដ្ឋបាល នៅក្នុងពិធីជប់លៀងនៅផ្ទះ ដោយផឹកស៊ី និងរាំ ហើយត្រូវផ្តន្ទាទោសដាក់ពន្ធនាគាររយៈពេល ១ឆ្នាំ និងពិន័យជាប្រាក់ ។[៣៦] ក្នុងករណីហួសហេតុស្រដៀងគ្នានេះមួយទៀតគឺ បុរសម្នាក់រស់នៅក្នុងខេត្តកំពង់ចាម ត្រូវបានតុលាការកាត់ទោសឱ្យជាប់ពន្ធនាគារមួយឆ្នាំពីបទផឹកស៊ីនៅមុខផ្ទះ និងជេរប្រមាថអាជ្ញាធរមូលដ្ឋាន ។[៣៧]

ទោសព្រហ្មទណ្ឌដែលធ្ងន់ធ្ងរហួសហេតុកើតចេញពីការរំលោភលើពាក្យបទល្មើសដែលសរសេរមិនច្បាស់ ដែលធ្វើឱ្យពាក្យនេះកាន់តែមានភាពស្មុគស្មាញ ។ ការដាក់ទណ្ឌកម្មកាន់តែច្រើន និងធ្ងន់ធ្ងរអាចអនុវត្តបានចំពោះសកម្មភាពបុគ្គល "ដែលនាំឱ្យមានការឆ្លងរាលដាលជំងឺកូវីដ-១៩ ដល់មនុស្សផ្សេងទៀត" ឬមាន "ផលប៉ះពាល់ធ្ងន់ធ្ងរដល់សុខភាពសាធារណៈ" ។[៣៨] ជាមួយនឹងភាពស្មុគស្មាញនៅក្នុងការកំណត់ឱ្យច្បាស់លាស់ថាការឆ្លងរាលដាលកើតចេញពីបុគ្គលណាម្នាក់ នៅពេលអ្នកកំពុងដោះស្រាយជាមួយនឹងមេរោគដែលឆ្លងតាមខ្យល់ ដែលជា "ការឆ្លងពីមនុស្សម្នាក់ផ្សេងទៀត" ពិតជាអាចយកមកធ្វើភស្តុតាងដែលលើសពីវិមតិសង្ស័យបានដែរឬយ៉ាងណា ។

លើសពីនេះទៅទៀត កង្វះភាពច្បាស់លាស់លើធាតុសំខាន់ៗដូចជា "ផលប៉ះពាល់ធ្ងន់ធ្ងរលើសុខភាពសាធារណៈ" គឺជាហានិភ័យនៃការកាត់ទោសដែលគ្មានភាពមិនស៊ីសង្វាក់គ្នា និងដោយ

[៣៤] មាត្រា ៥០៣ និងមាត្រា ៥០៤ នៃក្រមព្រហ្មទណ្ឌកម្ពុជា

[៣៥] មាត្រា ១១ នៃច្បាប់កូវីដ-១៩

[៣៦] ម៉ិច ដារ៉ា និង ណាត សុភាព, “ការចាប់ខ្លួនដោយសារជំងឺកូវីដ-១៩៖ ភាគី ដែលមិនពាក់ម៉ាស់ រត់ពន្ធលើរថយន្តសង្គ្រោះ”, VOD, ថ្ងៃទី២០ ខែមេសា ឆ្នាំ២០២១ ដកស្រង់ពី៖ https://vodenglish.news/covid-19-arrests-parties-not-wearing-masks-smuggling-on-ambulances/

[៣៧] ដូចខាងលើ

[៣៨] មើល ឧ. មាត្រា ៨ និង១០នៃច្បាប់កូវីដ-១៩

មិនត្រឹមត្រូវ ។ មាត្រាផ្សេងៗទៀតនៃច្បាប់កូវីដ-១៩ ដូចជាមាត្រា៩ ដែលមានការផ្តន្ទាទោសធ្ងន់ធ្ងរបំផុតដោយការដាក់ទោសពន្ធនាគាររហូតដល់ ២០ឆ្នាំ សម្រាប់ "ការចម្លងដោយចេតនា" នៃមេរោគកូវីដ-១៩ ទៅកាន់មនុស្សម្នាក់ផ្សេងទៀត " ប្រសិនបើអំពើនេះត្រូវបានប្រព្រឹត្តដោយមានការរៀបចំជាក្រុមមនុស្ស ឬអង្គការចាត់តាំង" បានចោទជាសំណួរស្រដៀងគ្នានេះទាក់ទងនឹងបន្ទុកនៃភស្តុតាង និងរបៀបដែល "ការចម្លងដោយចេតនា" អាចត្រូវបានបកស្រាយ និងបែងចែកពីការចម្លងដោយមិនប្រុងប្រយ័ត្ន ឬការធ្វេសប្រហែស ។[៣៩] ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌសម្រាប់ "ក្រុមដែលមានការរៀបចំ" ចោទជាការព្រួយបារម្ភយ៉ាងខ្លាំងលើសិទ្ធិអំណាចនៃការកាត់ទោសបុគ្គលណាម្នាក់ដោយមិនត្រឹមត្រូវចំពោះទង្វើដ៏សាមញ្ញដូចជា ការចូលរួមក្នុងការជួបប្រជុំដោយសន្តិវិធី ដែលមានការរក្សាគម្លាតសង្គម និងការពាក់ម៉ាស់ ប្រសិនបើបុគ្គលណាម្នាក់ដែលបានចូលរួមក្នុងបាតុកម្មក្រោយមកត្រូវគេធ្វើតេស្តវិជ្ជមានមេរោគកូវីដ-១៩ ។

## ការរំលោភសិទ្ធិតាមរយៈច្បាប់កូវីដ-១៩ ដូចដែលបានអនុវត្តកន្លងមក

### ក. ការរឹតត្បិតដោយមិនត្រឹមត្រូវលើសិទ្ធិសេរីភាពក្នុងការជួបប្រជុំដោយសន្តិវិធី និងសិទ្ធិក្នុងការបង្កើតសមាគម

ការអនុវត្តច្បាប់ និងអនុក្រឹត្យស្តីពីជំងឺកូវីដ-១៩ ក្នុងឆ្នាំដំបូងបណ្តាលឱ្យមានការរើសអើង និងមានការរឹតត្បិតដោយមិនចាំបាច់លើសិទ្ធិក្នុងការជួបប្រជុំដោយសន្តិវិធី និងសិទ្ធិក្នុងការបង្កើតសមាគមដែលមិនសមាមាត្រ ឬនៅក្នុងពេលខ្លះ ពាក់ព័ន្ធនឹងការការពារសុខភាពសាធារណៈ ។ ច្បាប់កូវីដ-១៩ ត្រូវបានអនុវត្តដោយមិនត្រឹមត្រូវ ដើម្បីបំបែក ឬទប់ស្កាត់ការតវ៉ាដែលរៀបចំឡើងដោយសកម្មជនសហជីព អ្នកការពារសិទ្ធិដីធ្លី និងប្រជាពលរដ្ឋដទៃទៀត ។ អ្នកតវ៉ាដីធ្លី និងកម្មករដែលធ្វើកូដកម្មត្រូវបានបញ្ជាឱ្យដាក់នៅដាច់ដោយឡែកពីគេក្រោមលក្ខខណ្ឌរើសអើង ហើយតំណាងសហគមន៍ដីធ្លី និងអ្នកដឹកនាំសហជីពមួយចំនួនត្រូវបានចាប់ខ្លួន ឃាត់ខ្លួន និងចោទប្រកាន់តាមច្បាប់កូវីដ-១៩នេះ ។

សិទ្ធិក្នុងការជួបប្រជុំ និងសិទ្ធិក្នុងការបង្កើតសមាគមមានចែងនៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា[៤០] ច្បាប់ស្តីពីការជួបប្រជុំដោយសន្តិវិធី[៤១] និងច្បាប់ជាតិ និងអន្តរជាតិផ្សេងទៀត រួមទាំងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ[៤២] ដែលកម្ពុជាជាប្រទេសរដ្ឋភាគី ។ អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិក្នុងការជួបប្រជុំដោយសន្តិវិធី និងសិទ្ធិក្នុងការបង្កើតសមាគមបានថ្លែងជាពិសេសអំពីកាតព្វកិច្ចបន្តរបស់រដ្ឋាភិបាលដើម្បីជួយសម្រួលដល់ការអនុវត្ត

[៣៩] ការទាក់ទងរបស់អ្នករាយការណ៍ពិសេស, លេខ ៤

[៤០] មាត្រា ៤១ និង៤២ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

[៤១] មាត្រា ២ នៃច្បាប់ស្តីពីការជួបប្រជុំដោយសន្តិវិធី នស/រកម/១២០៩/០២៥ ថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០០៩

[៤២] មាត្រា ២១ និង ២២ នៃ ICCPR

សិទ្ធិទាំងនេះដោយសេរីក្នុងអំឡុងពេលនៃការរាតត្បាតនៅក្នុងសេចក្តីថ្លែងការណ៍មួយ ដោយលើកឡើងថា "វាជាការចាំបាច់ដែលវិបត្តិកូវីដ-១៩ មិនត្រូវបានប្រើប្រាស់" ជាលេសដើម្បីគាបសង្កត់សិទ្ធិជាទូទៅ ឬសិទ្ធិក្នុងការជួបប្រជុំដោយសន្តិវិធី» ។[៤៣]

ទោះបីជាមានការដាស់តឿនបែបនេះក្តី ក៏ច្បាប់កូវីដ-១៩ ត្រូវបានអនុវត្តដោយរើសអើងចំពោះអ្នកការពារសិទ្ធិមនុស្ស អ្នកការពារសិទ្ធិដីធ្លី និងអ្នករិះគន់រដ្ឋាភិបាលផ្សេងទៀត ។ ជាឧទាហរណ៍ មាត្រា៥ នៃអនុក្រឹត្យស្តីពីវិធានការរដ្ឋបាល បានរំលោភបំពានលើ គោលការណ៍នៃវិធានការរឹតត្បិតតិចបំផុត ដោយផ្តល់អំណាចយ៉ាងទូលំទូលាយលើការរឹតត្បិត ឬហាមប្រាម "ការប្រជុំ ឬការជួបជុំមនុស្ស" មុននឹងបង្កើតករណីលើកលែងដែលមិនច្បាស់លាស់ចំពោះវិធានទូទៅ ។[៤៤] ដូច្នេះ អាជ្ញាធរមានសិទ្ធិអំណាចពេញលេញនៅក្នុងការសម្រេចចិត្តថាតើសិទ្ធិសេរីភាពក្នុងការជួបប្រជុំដោយសន្តិវិធី និងសិទ្ធិក្នុងការបង្កើតសមាគមត្រូវគេរឹតត្បិតនៅពេលណា និងដោយរបៀបណា ។

ច្បាប់ និងអនុក្រឹត្យស្តីពីជំងឺកូវីដ-១៩ ត្រូវបានអនុវត្តតាមរបៀបនេះ ក្នុងគោលបំណងបំបិទសំឡេងសហជីពកម្មករក្នុងអំឡុងពេលកូដកម្មនៅណាហ្គាវើលដ៍ (សហជីពណាហ្គាវើលដ៍) ដែលជាកាស៊ីណូរបស់ជនជាតិម៉ាឡេស៊ី ដែលមានអាជ្ញាប័ណ្ណប្រតិបត្តិការផ្តាច់មុខនៅក្នុងរាជធានីភ្នំពេញ ។ អតីតកម្មករ និងកម្មករកំពុងបម្រើការងាររាប់រយនាក់ដែលមកពីសហជីពទ្រទ្រង់សិទ្ធិការងារនៃបុគ្គលិកកម្មករខ្មែរនៃក្រុមហ៊ុនណាហ្គាវើលដ៍ បានចាប់ផ្តើមធ្វើកូដកម្មនៅថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០២១ ដើម្បីឆ្លើយតបទៅនឹងការចរចាដែលបរាជ័យជុំវិញការផ្តល់សំណងមិនត្រឹមត្រូវ និងការបញ្ឈប់បុគ្គលិកដែលជាសមាជិក និងថ្នាក់ដឹកនាំសហជីពយ៉ាងអយុត្តិធម៌ ។

ខណៈពេលដែលសមាជិកសហជីពចំនួន៩ នាក់ត្រូវបានចាប់ខ្លួន និងចោទប្រកាន់តាមក្រមព្រហ្មទណ្ឌ នៅចុងខែធ្នូ ឆ្នាំ២០២១ និងដើមខែមករា ឆ្នាំ២០២២[៤៥] បុគ្គលិក និងសមាជិកសហជីពណាហ្គាវើលដ៍ ចំនួន៦ នាក់ផ្សេងទៀត ត្រូវបានចោទប្រកាន់ពីបទរារាំងការអនុវត្តវិធានការតាមមាត្រា១១ នៃច្បាប់កូវីដ-១៩ ក្នុងខែកុម្ភៈ ឆ្នាំ២០២២ ។[៤៦] បើតាមច្បាប់កូវីដ-១៩ ការចោទប្រកាន់ទៅលើ

---

[៤៣] លោក Clément Voule អ្នកជំនាញអង្គការសហប្រជាជាតិស្តីពីសិទ្ធិសេរីភាពក្នុងការជួបប្រជុំដោយសន្តិវិធី និងសិទ្ធិក្នុងការបង្កើតសមាគម, "ការឆ្លើយតបរបស់រដ្ឋចំពោះការគំរាមកំហែងរបស់ជំងឺកូវីដ-១៩ មិនគួរបញ្ឈប់សេរីភាពក្នុងការជួបប្រជុំ និងសិទ្ធិក្នុងការបង្កើតសមាគម" (២០២០) ដកស្រង់ពី៖ https://www.ohchr.org/en/statements/2020/04/states-responses-covid-19-threat-should-not-halt-freedoms-assembly-and?LangID=E&NewsID=25788

[៤៤] មាត្រា ៥ នៃច្បាប់កូវីដ-១៩ (សេចក្តីបញ្ជាក់គួរបន្ថែម)

[៤៥] "ប្រធានរបស់ LRSU, សកម្មជនសហជីពត្រូវបានបញ្ជូនទៅឃុំខ្លួនបណ្តោះអាសន្នក្រោមការចោទប្រកាន់ពីបទញុះញង់", លីកាដូ ចុះថ្ងៃទី៥ ខែមករា ឆ្នាំ២០២២ ដកស្រង់ពី៖ https://www.licadho-cambodia.org/flashnews.php?perm=304

[៤៦] "សមាជិករបស់ LRSU ត្រូវបានចាប់ខ្លួន ដាក់ពន្ធនាគារ", លីកាដូ ចុះថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០២២ ដកស្រង់ពី៖

អ្នកទាំងប្រាំមួយនាក់នេះ គឺគ្មានហេតុផលច្បាស់លាស់នោះទេ ។ សមាជិកសហជីពណាហ្គាវើលដ៏៣នាក់ ត្រូវបានចាប់ខ្លួនរួមជាមួយកម្មករដទៃទៀតនៅថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០២២ បន្ទាប់ពីបានចាកចេញពីទីកន្លែងដែលរៀបចំដោយអាជ្ញាធរ ជាទីកន្លែងដែលពួកគេបានដាក់ពាក្យធ្វើតេស្តរកមេរោគកូវីដ-១៩ ។ សហជីព ទាំងបីរូបរួមមាន លោក សេង វណ្ណារិទ្ធ លោក សៅ សម្បត្តិ និងលោក ជួប ចាន់ណាត ត្រូវបានឃុំខ្លួនបណ្តោះអាសន្ន ចាប់ពីថ្ងៃទី៩ ខែកុម្ភៈ រហូតដល់ថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២២ នៅពេលដែលពួកគេត្រូវបានដោះលែងឱ្យនៅក្រៅឃុំ ។ សកម្មជនសហជីព៣នាក់ផ្សេងទៀត ក៏ត្រូវបានចោទប្រកាន់តាមច្បាប់កូវីដ-១៩ ហើយសំណុំរឿងអ្នកទាំង៦រូបនេះនៅមិនទាន់ចាត់ការនៅឡើយ ។

លើសពីនេះទៀត ចាប់ពីដើមខែកុម្ភៈ ឆ្នាំ២០២២ មក អាជ្ញាធរបានប្រើប្រាស់ច្បាប់កូវីដ-១៩ ក្នុងលក្ខណៈរើសអើង ដើម្បីបំបែកកូដកម្មស្ទើរតែរៀងរាល់ថ្ងៃ ។ អាជ្ញាធរបានចាប់ផ្តើមអនុវត្តវិធានការសុខាភិបាល និងវិធានការរដ្ឋបាលដើម្បីហាមឃាត់ការធ្វើកូដកម្ម បន្ទាប់ពីកម្មករម្នាក់បានធ្វើតេស្តវិជ្ជមានមេរោគកូវីដ-១៩ បើទោះបីជាមានរបាយការណ៍បញ្ជាក់ថាកម្មកររូបនោះមិនបានចូលរួមក្នុងកូដកម្មរយៈពេលពីរសប្តាហ៍មុនការធ្វើតេស្តវិជ្ជមានរបស់នាងក្តី និងរូបថតជាច្រើនសន្លឹកដែលគេបានបង្ហោះយ៉ាងទូលំទូលាយបានបង្ហាញថាកូដកម្មត្រូវគេរៀបចំធ្វើនៅទីតាំងបើកខាងក្រៅ ហើយកម្មករទាំងអស់សុទ្ធតែបានពាក់ម៉ាស់ និងបានរក្សាគម្លាតសង្គម ។

នៅថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០២២ កម្មករត្រូវបានរារាំងពីការចូលរួមក្នុងកូដកម្ម ដោយត្រូវបង្ខំឱ្យឡើងរថយន្តក្រុង និងនាំយកទៅធ្វើតេស្តរកមេរោគកូវីដ-១៩ ។ បន្ទាប់ពីបានបញ្ជូនទៅធ្វើតេស្ត និងតម្រូវឱ្យអនុវត្តវិធានការដាក់ឱ្យនៅដាច់ដោយឡែកនៅផ្ទះ កម្មករសហជីពណាហ្គាវើលដ៏ បានព្យាយាមបន្តធ្វើកូដកម្ម តែត្រូវគេបង្ខំឱ្យឡើងលើរថយន្តក្រុង និងដឹកជញ្ជូនយកទៅកន្លែងធ្វើចត្តាឡីស័ករបស់អាជ្ញាធរ ។[៤៧] នៅចន្លោះដើមខែកុម្ភៈ និងពាក់កណ្តាលខែមីនា ឆ្នាំ២០២២ អាជ្ញាធរបានឃុំខ្លួនកម្មកររបស់សហជីពណាហ្គាវើលដ៏រាប់រយនាក់នៅមជ្ឈមណ្ឌលធ្វើចត្តាឡីស័ករយៈពេលមួយយប់ ឬជាច្រើនថ្ងៃ ជាញឹកញាប់បន្ទាប់ពីបានប្រើកម្លាំងខុសច្បាប់ដើម្បីរុញច្រាន និងអូសពួកគេឱ្យចូលទៅក្នុងរថយន្តក្រុង ។ នៅពាក់កណ្តាលខែមីនា អាជ្ញាធរបានចាប់ផ្តើមប្រើប្រាស់រថយន្តក្រុងដើម្បីដឹកកម្មករពីកន្លែងធ្វើកូដកម្មទៅកាន់ជាយក្រុង ដែលពេលនោះពួកគេគ្មានជម្រើសអ្វីក្រៅពីរៀបចំ និងចេញថ្លៃធ្វើដំណើរទៅផ្ទះវិញដោយខ្លួនឯង ។ ជាក់ស្តែង ការបង្ខំឱ្យជិះរថយន្តក្រុងបង្ហាញពីការផ្តល់សិទ្ធិសម្រេចធំធេងដល់អាជ្ញាធរនៅក្នុងការប្រើប្រាស់ស្ទើរគ្រប់មធ្យោបាយដើម្បីរឹតត្បិតសិទ្ធិសេរីភាពក្នុងការជួបប្រជុំ និងសិទ្ធិ

https://www.licadho-cambodia.org/flashnews.php?perm=305

[៤៧] "ចាប់ខ្លួនកូដករនៅណាហ្គាវើលចំនួន ៦៤នាក់, បានបញ្ជូនទៅមជ្ឈមណ្ឌលកូវីដ-១៩", លីកាដូ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២២ ដកស្រង់ពី៖
https://www.licadho-cambodia.org/flashnews.php?perm=306

ក្នុងការបង្កើតសមាគម ដែលនេះជាលទ្ធផលនៃការចែងមិនច្បាស់លាស់ និងផ្តល់អំណាចហួសហេតុ នៅក្នុងច្បាប់ និងអនុក្រឹត្យស្តីពីកូវីដ-១៩ ។[៩៨] ការរារាំងដល់ការធ្វើកូដកម្ម និងការបង្ខំឱ្យចូលរថយន្តក្រុងនៅតែបន្តអនុវត្តចំពោះគ្រប់ការប្រមូលផ្តុំដែលគ្រោងរៀបចំដោយក្រុមកូដករ រហូតដល់ដើមខែកក្កដា ឆ្នាំ២០២២ ។

វិធានការកូវីដ-១៩ ដែលបានប្រើប្រាស់ប្រឆាំងនឹងកូដកម្មដែលធ្វើឡើងដោយកម្មករសហជីពណាហ្គាវើលដ៍ គឺហួសពីពិធីសារដែលមានចែងសម្រាប់សាធារណជនទូទៅ ដូច្នេះហើយទើបគេអាចសន្និដ្ឋានបានថាជាការរើសអើង ។ អ្នកជំនាញសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិចំនួនប្រាំរូបបានចាត់ទុកការប្រព្រឹត្តចំពោះកម្មករសហជីពណាហ្គាវើលដ៍កាលពីដើមខែកុម្ភៈថា មិនសមហេតុផល មិនមានភាពចាំបាច់ និងមិនសមស្របទៅនឹងកាលៈទេសៈ ហើយពួកគេបានលើកឡើងថា "អាជ្ញាធរហាក់ដូចជាខំបង្ហាញថា សកម្មភាពរារាំង ទៅលើការតវ៉ាដើម្បីសិទ្ធិការងារដោយសន្តិវិធីនិងស្របច្បាប់ គឺជាការចាត់វិធានការដើម្បីការពារសុខភាពសាធារណៈ" ។[៩៩]

សកម្មជនជាច្រើនរូបផ្សេងទៀតក៏ត្រូវបានគេដាក់គោលដៅ ដោយការជ្រៀតជ្រែកទាំងបំពានទៅលើសិទ្ធិនៅក្នុងការជួបប្រជុំដោយសន្តិវិធី និងសិទ្ធិក្នុងការបង្កើតសមាគម ។ កាលពីថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២១ ប្រជាពលរដ្ឋប្រមាណ ៦០នាក់ បានព្យាយាមប្រមូលផ្តុំគ្នាដោយសន្តិវិធី នៅតាមបណ្តោយផ្លូវលេខ១២០ ក្នុងសង្កាត់សំរោង ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ ដើម្បីស្វែងរកការចេញប័ណ្ណកម្មសិទ្ធិដីធ្លី និងសៀវភៅគ្រួសារ បន្ទាប់ពីដីដែលពួកគេធ្លាប់កាន់កាប់នៅក្បែរបឹងតាមោកត្រូវបានកាត់ចូលជាដីកម្មសិទ្ធិរដ្ឋ ។ អាជ្ញាធរខណ្ឌព្រែកព្នៅ បានបញ្ជាឱ្យអ្នកតវ៉ា រួមទាំងតំណាងសហគមន៍សំរោងត្បូង បំបែកខ្លួន ដោយលើកហេតុផលថា បាតុកម្មរបស់ពួកគេគឺបានបំពានលើអនុក្រឹត្យស្តីពីវិធានការរដ្ឋបាល ។

កាលពីថ្ងៃទី២ ខែសីហា ឆ្នាំ២០២១ ប្រជាពលរដ្ឋរាប់រយគ្រួសារបានប្រមូលផ្តុំគ្នានៅស្រុកស្វាយជ្រំ ខេត្តស្វាយរៀង ដើម្បីតវ៉ាប្រឆាំងនឹងការព្យាយាមបង្ខំឱ្យពួកគេទទួលយកសំណងមិនសមស្របសម្រាប់ការរឹបអូសយកដីស្រែចំការជិត១០០ ហិកតា ។ កាលពីថ្ងៃទី៤ ខែសីហា អ្នកស្រី យស់ សោភ័ណ្ឌ និងអ្នកស្រី ឥន សូត្រ តំណាងសហគមន៍ពីររូបនៃសហគមន៍សាមគ្គីចេកមាស ក្នុងខេត្តស្វាយរៀង ត្រូវបានអាជ្ញាធរស្រុក ផាកពិន័យម្នាក់ៗជាប្រាក់ចំនួន២លានរៀល (៥០០ ដុល្លារសហរដ្ឋ

---

[៩៨] សូមមើល ឧ. សេចក្តីជូនដំណឹង, អាជ្ញាធរក្រុងភ្នំពេញ ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២២ (យោងជំងឺកូវីដ-១៩ ជាហេតុផលសម្រាប់ការរំខានដល់ទីតាំងនៃកូដកម្ម)

[៩៩] "កម្ពុជា៖ វិធានការបង្ក្រាបថ្មីប្រឆាំងនឹងកម្មករធ្វើកូដកម្មគឺ "មិនសមហេតុផល" – អ្នកជំនាញសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ" OHCHR ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២២ ដកស្រង់ពី៖ https://www.ohchr.org/en/press-releases/2022/02/cambodia-stifling-new-measures-against-striking-workers-are-unjustified-un

អាមេរិក) តាមច្បាប់កូវីដ-១៩ ក្រោយពីចូលរួមការតវ៉ាមួយ ដោយសារអ្នកតវ៉ាមួយចំនួន ត្រូវបានចោទថាមិនបានពាក់ម៉ាស់ ឬរក្សាគម្លាតសង្គម ។ កាលពីថ្ងៃទី១៣ ខែសីហា ប្រជាពលរដ្ឋប្រមាណ ៦០គ្រួសារ មកពីភូមិចេក និងភូមិធ្នង់ ត្រូវបានបង្គាប់ឱ្យធ្វើចត្តាឡីស័ករយៈពេល ១៤ថ្ងៃ ក្រោមលេសថាអ្នកភូមិម្នាក់ដែលចូលរួមការតវ៉ាបានធ្វើតេស្តវិជ្ជមានមេរោគកូវីដ-១៩ ។[៥០]

នៅថ្ងៃទី២៧ ខែសីហា អ្នកស្រី យស់ សោភ័ណ្ឌ និងអ្នកស្រី ឥន សូត្រ ត្រូវបានចាប់ខ្លួន ។ នៅថ្ងៃទី២៨ ខែសីហា តំណាងសហគមន៍ទាំងពីររូបត្រូវបានចោទប្រកាន់តាមមាត្រា១០ និងមាត្រា១១ នៃច្បាប់កូវីដ-១៩ ពីបទមិនគោរពវិធានការរដ្ឋបាល និងការរារាំងដល់ការអនុវត្តវិធានការ ហើយត្រូវបានបញ្ជូនទៅឃុំខ្លួនបណ្ដោះអាសន្នក្នុងពន្ធនាគារ ។[៥១] បន្ទាប់ពីចាប់ខ្លួនអ្នកទាំងពីរ ពលរដ្ឋជាង១០០គ្រួសារនៅក្នុងសហគមន៍ដែលរងផលប៉ះពាល់បានទទួលយកការផ្ដល់សំណងរបស់រដ្ឋាភិបាល បើទោះបីជាមានការជំទាស់ពីមុនក៏ដោយ ។ អ្នកស្រី យស់ សោភ័ណ្ឌ និងអ្នកស្រី ឥន សូត្រ ត្រូវបានដោះលែងឱ្យនៅក្រៅឃុំនៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២១ ដោយត្រូវកាត់ទោសនៅថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២២ ។ តុលាការបានចេញសាលក្រមរួចហើយ ប៉ុន្តែមិនបានបង្ហាញសាលក្រមនោះជាសាធារណៈនោះទេ ។

គេអាចមើលឃើញទុកជាមុនថា អាជ្ញាធរនឹងរំលោភលើសិទ្ធិអំណាចដ៏ទូលំទូលាយ ដើម្បីជ្រៀតជ្រែកលើសិទ្ធិជាមូលដ្ឋាន ។ ជាឧទាហរណ៍ កាលពីខែមេសា ឆ្នាំ២០២០ មន្ត្រីនគរបាល មន្ត្រីក្រសួងបរិស្ថាន និងអាជ្ញាធរមូលដ្ឋានជាច្រើនបានរារាំងក្រុមយុវជន បុគ្គលិកអង្គការក្រៅរដ្ឋាភិបាល និងសមាជិកសហគមន៍ប្រមាណ៤០ នាក់ មិនឱ្យប្រារព្ធខួបលើកទី៨ នៃឃាតកម្មលើសកម្មជនបរិស្ថាន លោក ឈុត វុទ្ធី នៅក្នុងព្រៃឡង់ ។ អាជ្ញាធរបានលើកយកហានិភ័យនៃការឆ្លងរីករាលដាលជំងឺកូវីដ-១៩ ធ្វើជាមូលដ្ឋានសម្រាប់ការហាមឃាត់ការជួបប្រជុំដោយសន្តិវិធី បើទោះបីជាមានការជួបប្រជុំនៅទីតាំងខាងក្រៅក៏ដោយ ។ ទាហានប្រមាណ ៥០នាក់ ត្រូវបានដាក់ពង្រាយដើម្បីស្វែងរកសកម្មជនបរិស្ថានចំនួន ៥នាក់ ដែលបានចូលព្រៃ ដែលក្នុងនោះមានលោក អ៊ូច ឡេង ជាម្ចាស់រង្វាន់វីរជនបរិស្ថានពិភពលោក ។ ទោះបីជាមានភស្តុតាងយ៉ាងច្បាស់ដែលព្រមានអំពីការរំលោភបំពានអំណាចរបស់អាជ្ញាធរក្នុងការរឹតត្បិតសេរីភាពជាមូលដ្ឋានក្រោមរូបភាពនៃវិបត្តិសុខភាពសាធារណៈក្ដី ក៏ច្បាប់និងអនុក្រឹត្យស្ដីពីកូវីដ-១៩ ត្រូវបានអនុម័តយ៉ាងប្រញាប់ប្រញាល់ដើម្បីបង្កើតច្បាប់ និងពង្រឹងអំណាច ។

---

[៥០] ជា សុខនី "អាជ្ញាធរខេត្តស្វាយរៀងដាក់អ្នកតវ៉ាក្នុងជម្លោះដីធ្លីតាមប្រឡាយទឹក ឱ្យធ្វើចត្តាឡីស័ក" ដោយខេមបូចា ថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២១ ដកស្រង់ពី៖ https://cambojanews.com/svay-rieng-provincial-authorities-place-canal-land-dispute-protestors-in-covid-19-quarantine/

[៥១] "អ្នកតំណាងសហគមន៍ពីរនាក់ត្រូវបានចាប់ខ្លួន, ចោទប្រកាន់តាមច្បាប់កូវីដ-១៩", លីកាដូ ថ្ងៃទី២៨ ខែសីហា ឆ្នាំ២០២១ ដកស្រង់ពី៖ https://www.licadho-cambodia.org/flashnews.php?perm=290

## ខ- ការរឹតត្បិតដោយមិនត្រឹមត្រូវលើសេរីភាពក្នុងការបញ្ចេញមតិ

បទចោទនៃច្បាប់កូវីដ-១៩ ត្រូវបានគេប្រើប្រាស់ដោយមិនត្រឹមត្រូវប្រឆាំងនឹងអ្នកសារព័ត៌មាន និងបុគ្គលដែលបញ្ចេញមតិរិះគន់រដ្ឋាភិបាល ដោយអនុវត្តការរឹតត្បិតដែលមិនចាំបាច់ និងមិនសមស្រប លើសេរីភាពក្នុងការបញ្ចេញមតិ ។ សិទ្ធិក្នុងការបញ្ចេញមតិត្រូវបានលើកកម្ពស់ និងការពារនៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា[៥២] និងច្បាប់អន្តរជាតិ រួមទាំងមាត្រា១៩ នៃ ICCPR ផងដែរ ។[៥៣] កាលពីខែឧសភា ឆ្នាំ២០២១ អង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិចំនួន១២បានចេញសេចក្ដីថ្លែងការណ៍ជាសាធារណៈដោយអំពាវនាវឱ្យរដ្ឋាភិបាលកម្ពុជាធ្វើវិសោធនកម្ម ឬលុបចោលច្បាប់កូវីដ-១៩ បញ្ឈប់ការយាយីដល់អ្នកសារព័ត៌មាន និងអ្នករិះគន់ និងប្រើប្រាស់វិធានការដែលប៉ះពាល់តិចតួចបំផុតដល់សិទ្ធិក្នុងការបញ្ចេញមតិ ។[៥៤]

នៅចន្លោះខែមេសា ដល់ខែកក្កដា ឆ្នាំ២០២១ ភ្លាមៗបន្ទាប់ពីការប្រកាសឱ្យប្រើច្បាប់នេះ បុគ្គលយ៉ាងតិចណាស់ចំនួន៦នាក់ត្រូវបានចាប់ខ្លួនតាមច្បាប់កូវីដ-១៩ ដោយសារការបញ្ចេញមតិ ឬចែកចាយព័ត៌មានដែលគេយល់ថាជាការរិះគន់ទៅលើចំណាត់ការរបស់រដ្ឋាភិបាលចំពោះជំងឺរាតត្បាត ហើយត្រូវបានចោទប្រកាន់តាមមាត្រា១១ ពីបទរារាំងដល់ការអនុវត្តវិធានការ ដែលមាត្រានេះមានលក្ខណៈទូលំទូលាយ និងមានភាពមិនច្បាស់លាស់ ។ បុគ្គលទាំង ៦នាក់នេះត្រូវបានចោទប្រកាន់ដោយផ្អែកលើសកម្មភាពរបស់ពួកគេនៅលើប្រព័ន្ធផ្សព្វផ្សាយសង្គម ដូចជាការបង្ហោះវីដេអូរិះគន់ទៅលើចំណាត់ការរបស់រដ្ឋាភិបាលចំពោះជំងឺរាតត្បាតនៅលើបណ្ដាញសង្គម TikTok ជាដើម ។ តួយ៉ាង លោក កៅ ពិសិដ្ឋ អ្នកឆ្លើយឆ្លងព័ត៌មានរបស់គេហទំព័រព័ត៌មានមួយនៅខេត្តសៀមរាបគឺ Tannhektar ត្រូវបានចាប់ខ្លួននៅថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១ ហើយក្រោយមកត្រូវបានកាត់ទោសពីបទញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋ ជាអាទិ៍ និងបទរារាំងដល់ការអនុវត្តវិធានការ តាមបញ្ញត្តិមាត្រា១១នៃច្បាប់ស្ដីពីកូវីដ-១៩ បន្ទាប់ពីបានបញ្ចេញមតិលើទំព័រហ្វេសប៊ុករបស់លោក ពាក់ព័ន្ធនឹងការសម្រេចរបស់រដ្ឋាភិបាលក្នុងការប្រើប្រាស់វ៉ាក់សាំង Sinopharm និង Sinovac ។[៥៥] លោក កៅ ពិសិដ្ឋ ត្រូវបានកាត់ទោសឱ្យជាប់ពន្ធនាគាររយៈពេល ២ឆ្នាំ ហើយការផ្តន្ទាទោសលើរូបលោកត្រូវបានតម្កល់ដោយសាលាឧទ្ធរណ៍

---

[៥២] មាត្រា ៤១ នៃរដ្ឋធម្មនុញ្ញរបស់ព្រះរាជាណាចក្រកម្ពុជា

[៥៣] មាត្រា ១៩ នៃ ICCPR

[៥៤] "កម្ពុជា៖ បញ្ឈប់ការបំបិទសំឡេងរិះគន់លើជំងឺកូវីដ-១៩" សេចក្ដីថ្លែងការណ៍រួម ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២១ ដកស្រង់ពី៖ https://www.amnesty.org/en/documents/asa23/4183/2021/en/

[៥៥] «អ្នកយកព័ត៌មាននៅកម្ពុជាប្រឈមនឹងការជាប់ពន្ធនាគាររយៈពេលប្រាំឆ្នាំពីបទធ្វើអត្ថាធិប្បាយអំពីវ៉ាក់សាំង» អ្នកកាសែតគ្មានព្រំដែន ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២១ ដកស្រង់ពី៖ https://rsf.org/en/cambodian-reporter-facing-five-years-prison-comment-about-vaccines

បាត់ដំបង កាលពីថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០២២ ។[៥៦] លោក ប៉ាន សុភី ជាកម្មករកសិដ្ឋានចិញ្ចឹមជ្រូកម្នាក់ទៀត ក៏ត្រូវបានគេចាប់ខ្លួនកាលពីថ្ងៃទី៩ ខែមេសា ឆ្នាំ២០២១ នៅក្នុងខេត្តកំពង់ស្ពឺ ដែលក្រោយមកត្រូវបានកាត់ទោសពីបទញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋ ជាអាទិ៍ និងបទរារាំងដល់ការអនុវត្តវិធានការ ដោយសារលោកបានបង្ហោះវីដេអូលើបណ្តាញសង្គម TikTok ដែលរិះគន់លើចំណាត់ការរបស់រដ្ឋាភិបាលចំពោះជំងឺរាតត្បាត ។ លោក ប៉ាន សុភី ត្រូវបានតុលាការកាត់ទោសឱ្យជាប់ពន្ធនាគាររយៈពេល១៨ ខែ ហើយលោកនៅតែជាប់ទោសនៅឡើយក្នុងខែកក្កដា ឆ្នាំ២០២២ ។

បទចោទនៃមាត្រា១១ នៃច្បាប់កូវីដ-១៩ គឺជាទោសជាប់ពន្ធនាគាររហូតដល់ ៣ឆ្នាំ និងពិន័យជាប្រាក់រហូតដល់១០ លានរៀល (ប្រមាណ ២.៥០០ ដុល្លារសហរដ្ឋអាមេរិក) ។ ប្រសិនបើអំពើនៃការរារាំងនេះបានបណ្តាលឱ្យមានការឆ្លងដល់អ្នកដទៃ ឬមាន "ផលប៉ះពាល់ធ្ងន់ធ្ងរដល់សុខភាពសាធារណៈ" ដែលមិនត្រូវបានបកស្រាយ បុគ្គលនោះអាចជាប់ពន្ធនាគាររហូតដល់៥ឆ្នាំ និងពិន័យជាប្រាក់រហូតដល់ ២០លានរៀល (ប្រហែល ៥.០០០ ដុល្លារសហរដ្ឋអាមេរិក) ។

ចុងចោទជាច្រើនរូប ត្រូវបានគេចោទប្រកាន់តាមក្រមព្រហ្មទណ្ឌ[៥៧] និងច្បាប់កូវីដ-១៩ ។ ការកំណត់កម្រិតនៃបទចោទច្រើនប្រភេទ ដែលបទចោទនីមួយៗមានទោសជាប់ពន្ធនាគារ អាចបញ្ជាក់បន្ថែមទៀតថា វិធានការបែបនេះ មិនសមស្របនៅក្នុងការឆ្លើយតបទៅនឹងការបញ្ចេញមតិរិះគន់រដ្ឋាភិបាលតាមប្រព័ន្ធអ៊ីនធឺណិត ហើយក៏មិនមែនជាវិធានការដែលមានភាពចាំបាច់នោះដែរ ។ ជាងនេះទៅទៀត គណៈកម្មាធិការសិទ្ធិមនុស្សបានគូសបញ្ជាក់នៅក្នុងមតិទូទៅទី៣៤ ថាការដាក់ទោសទណ្ឌចំពោះការបញ្ចេញមតិយោបល់មួយ គឺមិនសមស្របនឹងស្មារតី និងខ្លឹមសារនៃមាត្រា១៩ នៃ ICCPR ក៏ដូចជាកិច្ចខិតខំប្រឹងប្រែងណាមួយដើម្បីបង្ខិតបង្ខំការបញ្ចេញ ឬការមិនបញ្ចេញមតិ ។[៥៨]

ការកម្រិតតឹងរ៉ឹង និងការដាកពិន័យធ្ងន់ធ្ងរលើការទំនាក់ទំនងដោយសេរីនៃព័ត៌មាន និងមតិជាពិសេសសមាជិកនៃប្រព័ន្ធផ្សព្វផ្សាយ ដូចជាលោក កៅ ពិសិដ្ឋ គឺជាការរឹតត្បិតដែលមិនមានភាពចាំបាច់ និងជាការគួរឱ្យព្រួយបារម្ភបំផុត ។ ព័ត៌មានអំពីរបៀបដែលច្បាប់កូវីដ-១៩ ត្រូវបានអនុវត្តក្នុងឆ្នាំដំបូងគាំទ្រការសន្និដ្ឋានថាច្បាប់នេះជាឧបករណ៍បន្ថែមសម្រាប់ការតាមដាន និងការគាបសង្កត់ប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ និងអ្នកសារព័ត៌មាន ។ បទប្បញ្ញត្តិផ្លូវច្បាប់ផ្សេងទៀត ដូចជាបទឧក្រិដ្ឋនៃការញុះញង់ ក៏ត្រូវបានគេប្រើយ៉ាងទូលំទូលាយនៅក្នុងឆ្នាំដដែល ដើម្បីចាប់ខ្លួន កាត់ទោស និង

[៥៦] ងាយ ណៃ "សាលាឧទ្ធរណ៍តម្កល់ការផ្តន្ទាទោសលើអ្នកកាសែតដែលរិះគន់អំពីវ៉ាក់សាំង" ដោយខេមបូចា ថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០២២ ដកស្រង់ពីៈ https://cambojanews.com/appeal-court-upholds-sentence-against-journalist-who-criticized-vaccines/

[៥៧] មាត្រា ៤៩៤ និង៤៩៥ (បទញុះញង់) នៃក្រមព្រហ្មទណ្ឌកម្ពុជា

[៥៨] សេចក្តីអធិប្បាយទូទៅលេខ៣៤ នៅកថាខណ្ឌទី ៩–១០

ដាក់ពន្ធនាគារ និងសូម្បីតែបណ្តេញអ្នកសារព័ត៌មានចេញពីប្រទេស ចំពោះការរាយការណ៍ ឬការបញ្ចេញមតិលើការឆ្លើយតបរបស់រដ្ឋាភិបាលលើជំងឺកូវីដ-១៩ ។ លើសពីនេះទៅទៀត អ្នកសារព័ត៌មានត្រូវបានហាមឃាត់មិនឱ្យរាយការណ៍ពីតំបន់ក្រហមដោយគ្មានការអនុញ្ញាតពីរដ្ឋាភិបាល និងរងការគំរាមកំហែងចំពោះការផ្សព្វផ្សាយព័ត៌មានណាដែលអាច "បង្កភាពចលាចលក្នុងសង្គម" ។[៥៩]

## គ.ការរឹតត្បិតដោយមិនត្រឹមត្រូវលើសេរីភាពក្នុងការធ្វើដំណើរ និងសិទ្ធិទទួលបានការថែទាំសុខភាព

ការរឹតត្បិតការធ្វើដំណើរ បម្រាមគោចរ និងការបិទខ្ទប់ ត្រូវបានដាក់ចេញនៅទូទាំងប្រទេសចន្លោះខែមេសា ដល់ខែកញ្ញា ឆ្នាំ២០២១ ជាពិសេសនៅទីក្រុងភ្នំពេញ ខេត្តព្រះសីហនុ ក្រុងប៉ោយប៉ែត ខេត្តកណ្តាល និងខេត្តសៀមរាប ដែលវិធានការទាំងនេះប៉ះពាល់ដល់ប្រជាជនរាប់សែននាក់ ។ ក្នុងពេលមួយនោះ មន្ត្រីនគរបាលនៅតាមតំបន់មួយចំនួនក្នុងរាជធានីភ្នំពេញបានប្រើដើមឫស្សីវាយប្រជាពលរដ្ឋដែលត្រូវបានចោទប្រកាន់ថាបាន បំពានវិធានការបិទខ្ទប់ ដោយនេះជាការរំលោភអំណាចយ៉ាងព្រៃផ្សៃ ដែលអំពើនេះដំបូងឡើយត្រូវបានការពារដោយអភិបាលរាជធានីភ្នំពេញ ។[៦០] ការបិទខ្ទប់បានកើតឡើងដោយអនុលោមតាមមាត្រា៤ នៃច្បាប់កូវីដ-១៩ ដែលអនុញ្ញាតឱ្យមានការបិទខ្ទប់យ៉ាងទូលំទូលាយនៃ "តំបន់ ឬទីកន្លែងដែលមានមេរោគកូវីដ-១៩" ដោយមិនបានកំណត់ច្បាស់លាស់ ។

នៅក្រោមប្រព័ន្ធបិទខ្ទប់ដែលមានកំណត់ពណ៌ "តំបន់ក្រហម" គឺពាក់ព័ន្ធនឹងការរឹតត្បិតតឹងរ៉ឹងបំផុត ដោយហាមប្រាមការធ្វើដំណើរ លើកលែងចំពោះការធ្វើដំណើរដោយមូលហេតុសុខភាពបន្ទាន់ ។ សេរីភាពក្នុងការធ្វើដំណើរបានផ្សារភ្ជាប់ជាមួយនឹងសេរីភាព និងសេចក្តីថ្លៃថ្នូររបស់បុគ្គល ហើយមានសារៈសំខាន់ចំពោះការអនុវត្តសិទ្ធិជាមូលដ្ឋានផ្សេងទៀតដូចជា សិទ្ធិការងារ សិទ្ធិគ្រួសារ និងសិទ្ធិទទួលបានការថែទាំសុខភាព ។[៦១] ការរឹតត្បិតលើសេរីភាពក្នុងការធ្វើដំណើរ ដែលបានធ្វើឡើងដោយផ្អែកលើហេតុផលនៃសុខភាពសាធារណៈ ក្នុងករណីដែលមានការអនុញ្ញាត ត្រូវតែមានភាពចាំបាច់នៅក្នុងសង្គមប្រជាធិបតេយ្យ និងភាពសមស្រប និងស៊ីចង្វាក់គ្នាជាមួយនឹងសិទ្ធិផ្សេងៗទៀត ។[៦២]

---

[៥៩] "កម្ពុជា៖ បញ្ឈប់ការបំបិទសំឡេងរិះគន់លើជំងឺកូវីដ-១៩" សេចក្តីថ្លែងការណ៍រួម ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២១ ដកស្រង់ពី៖ https://www.amnesty.org/en/documents/asa23/4183/2021/en/

[៦០] អួច សូនី "នគរបាលប្រើប្រាស់ដំបងវាយអ្នកបំពានវិធានការបិទខ្ទប់ និងឃាត់ខ្លួនមនុស្ស១០០នាក់" ដោយវីអូឌី ថ្ងៃទី២១ ខែមេសា ឆ្នាំ២០២១ ដកស្រង់ពី៖ https://vodenglish.news/police-introduce-canes-for-beating-lockdown-violators-100-arrested/

[៦១] មាត្រា ៣១ មាត្រា៣២ និងមាត្រា៤០ នៃរដ្ឋធម្មនុញ្ញរបស់ព្រះរាជាណាចក្រកម្ពុជា ។ មាត្រា ១២ នៃICCPR ។ មាត្រា ១២ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ (ICESCR) ឆ្នាំ ១៩៧៦ ។ ប្រទេសកម្ពុជាបានចុះហត្ថលេខាលើ ICESCR ក្នុងឆ្នាំ១៩៨០ និងបានផ្តល់សច្ចាប័នលើសន្ធិសញ្ញានេះនៅថ្ងៃទី២៦ ខែឧសភា ឆ្នាំ១៩៩២ ។

[៦២] មាត្រា ១២(៣)នៃ ICCPR ។ សេចក្តីអត្ថាធិប្បាយទូទៅលេខ២៧ នៅកថាខ័ណ្ឌ២ ១១ និង ១៥

ដូចគ្នាទៅនឹងការកម្រិតលើសិទ្ធិមនុស្សផ្សេងទៀតដែរ វិធានការរឹតត្បិតតិចតួចបំផុតគួរត្រូវបានអនុម័ត ដើម្បីធានាថាសិទ្ធិនៅតែត្រូវបានការពារ ហើយការរឹតត្បិតណាមួយត្រូវតែបានកំណត់យ៉ាងច្បាស់លាស់ ដើម្បីការពារការបំពានលើសិទ្ធិក្នុងការសម្រេចចិត្ត ។[៦៣]

ទោះជាយ៉ាងនេះក្តី ច្បាប់កូវីដ-១៩ និងអនុក្រឹត្យស្តីពីវិធានការរដ្ឋបាល មានលក្ខណៈផ្ទុយនឹងបទដ្ឋាន និងករណីលើកលែងផ្សេងទៀត ដោយចាប់ផ្តើមពីការផ្តល់អំណាចយ៉ាងទំលំទូលាយក្នុងការដាក់កម្រិតលើការធ្វើដំណើរទាំងអស់ ហើយបន្ទាប់មកបានចែងពីករណីលើកលែងមួយចំនួន ដែលមិនមានភាពច្បាស់លាស់ ។[៦៤] ការតាក់តែងច្បាប់ ដែលមិនស្របនឹងបទដ្ឋានអន្តរជាតិ គឺផ្តល់អំណាចឱ្យអាជ្ញាធរក្នុងការបង្កើតតំបន់បិទខ្ទប់ ដូចជាតំបន់ក្រហម ដែលមានការជូនដំណឹងតិចតួច និងការរឹតត្បិតដ៏តឹងរ៉ឹង និងយ៉ាងទូលំទូលាយពេក ។ វិធានការបិទខ្ទប់មិនត្រូវបានរៀបចំឡើងដោយប្រុងប្រយ័ត្ន ឬពិភាក្សាឱ្យបានហ្មត់ចត់ក្នុងការអនុវត្ត ដើម្បីកាត់បន្ថយផលប៉ះពាល់អវិជ្ជមានលើពលរដ្ឋនោះទេ និងបានផ្តល់សិទ្ធិអំណាចក្នុងការសម្រេចចិត្តដោយមិនសមស្របដល់អាជ្ញាធរ ដើម្បីកំណត់ថាតើ ការលើកលែងចំពោះសេរីភាពក្នុងការធ្វើដំណើរគួរត្រូវអនុវត្តនៅពេលណា និងដោយរបៀបណា ។

ជាឧទាហរណ៍ ទោះបីជាមាត្រា៤ នៃអនុក្រឹត្យស្តីពីវិធានការរដ្ឋបាលកំណត់ការធ្វើដំណើរដោយសារហេតុផលសុខភាពបន្ទាន់ជាករណីលើកលែងចំពោះការបិទខ្ទប់ក្តី ក៏ជាក់ស្តែងប្រជាពលរដ្ឋជាច្រើនត្រូវបានរារាំងពីការទទួលបានសេវាថែទាំសុខភាព និងនៅក្នុងករណីខ្លះ ពួកគេមិនត្រូវបានអនុញ្ញាតឱ្យចេញពីផ្ទះតែម្តង ។ ជាឧទាហរណ៍ នៅក្នុងខែឧសភា ឆ្នាំ២០២១ ម្តាយអាយុ១៧ ឆ្នាំម្នាក់បានសម្រាលកូននៅផ្ទះ ដោយសារតែការរឹតត្បិតនៃការបិទខ្ទប់ ដែលករណីនេះបង្ហាញពីហានិភ័យដែលមិនអាចទទួលយកបានចំពោះអាយុជីវិត និងសុខភាពរបស់ម្តាយ និងទារក ។ នៅពេលរដ្ឋាភិបាលបានរំលោភលើកាតព្វកិច្ចរបស់ខ្លួនចំពោះវិធានការដែលបានដាក់ចេញក្នុងការរក្សាសិទ្ធិជាមូលដ្ឋាន ស្ថាប័នផ្សេងទៀតត្រូវបង្ខំចិត្តដណ្តើមគ្នាដើម្បីបំពេញចន្លោះខ្វះខាតតាមរយៈការផ្តល់នូវសេវាសុខាភិបាល និងឱសថតាមមធ្យោបាយអនឡាញ ឬរក្សាគម្លាតសង្គម ។

វិធានការរដ្ឋបាលរបស់រដ្ឋាភិបាល គឺផ្ទុយពីគោលបំណងនៃច្បាប់កូវីដ-១៩ និងអនុក្រឹត្យដើម្បីការពារអាយុជីវិតប្រជាពលរដ្ឋ សុខភាពសាធារណៈ និងការកាត់បន្ថយផលប៉ះពាល់នៃជំងឺនេះមកលើវិស័យសង្គម និងសេដ្ឋកិច្ច ។ ការបិទខ្ទប់ និងវិធានការរដ្ឋបាលពាក់ព័ន្ធដែលដាក់ចេញតាមច្បាប់នេះ បានបង្កឱ្យមានផលអវិជ្ជមានយ៉ាងធ្ងន់ធ្ងរ ប៉ះពាល់ដល់សិទ្ធិរបស់ប្រជាពលរដ្ឋក្នុងការទទួលបានកម្រិតស្តង់ដារខ្ពស់បំផុតនៃសុខភាពផ្លូវកាយ និងសុខភាពផ្លូវចិត្ត ។[៦៥] ប្រជាពលរដ្ឋរាប់សែននាក់ត្រូវបាន

[៦៣] សេចក្តីអត្ថាធិប្បាយទូទៅលេខ២៧ កថាខ័ណ្ឌលេខ ១៣-១៥

[៦៤] មាត្រា ៤ ច្បាប់កូវីដ-១៩, មាត្រា ៣ និង៤ នៃអនុក្រឹត្យស្តីពីវិធានការរដ្ឋបាល

[៦៥] មាត្រា ១២ នៃ ICESCR

រឹតត្បិតយ៉ាងតឹងរ៉ឹងក្នុងការទទួលបានអាហារ ឱសថ ការថែទាំសុខភាព ទំនិញ និងសេវាកម្មសំខាន់ៗផ្សេងទៀត ។ ប្រព័ន្ធផ្សព្វផ្សាយសង្គមបានបង្ហោះយ៉ាងជោកជាំនូវព័ត៌មានពាក់ព័ន្ធនឹងពលរដ្ឋដែលខ្វះខាតស្បៀងអាហារ និងរបស់របរប្រើប្រាស់ចាំបាច់ផ្សេងទៀត មិនតែប៉ុណ្ណោះអាជ្ញាធរបានរារាំងអង្គការមិនមែនរដ្ឋាភិបាល ក្រុមសប្បុរសធម៌ និងអង្គការសហប្រជាជាតិពីការផ្តល់ជំនួយដែលចាំបាច់ ។ ការវាយតម្លៃយ៉ាងឆាប់រហ័សដែលធ្វើឡើងដោយអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិនៅក្នុងខែឧសភា ឆ្នាំ២០២១ ស្តីពីរយៈពេលបិទខ្ទប់ក្នុងរាជធានីភ្នំពេញ បានរកឃើញថា៧៧% នៃប្រជាពលរដ្ឋរស់នៅតំបន់ក្រហមមានអាហារហូបចុកមិនគ្រប់គ្រាន់ ហើយមានតែ៤៣% ប៉ុណ្ណោះដែលទទួលបានជំនួយស្បៀងអាហារ ។[៦៦] បន្ទាប់ពីការពន្យារពេលយ៉ាងយូរ រដ្ឋាភិបាលនៅទីបំផុតបានអនុវត្តប្រព័ន្ធដើម្បីលក់ទំនិញចាំបាច់តិចតួចបំផុតពីហាងដែលគ្រប់គ្រងដោយរដ្ឋាភិបាល ។ កុមារស្ថិតក្នុងចំណោមជនងាយរងគ្រោះ មិនទទួលបានអាហារគ្រប់គ្រាន់ ទំនិញចាំបាច់ និងការថែទាំសុខភាព ខណៈដែលពួកគេត្រូវបានកាត់ផ្តាច់ពីការអប់រំ ។ ការរឹតត្បិតយ៉ាងធ្ងន់ធ្ងរលើសេរីភាពក្នុងការធ្វើដំណើរ ដែលត្រូវបានអនុវត្តកន្លងមក ទំនងជាមានផលប៉ះពាល់មិនសមាមាត្រលើសុខភាពផ្លូវចិត្ត និងរាងកាយ និងការលូតលាស់របស់កុមារផងដែរ ។

## ឃ. ការរំលោភសិទ្ធិផ្សេងៗនៅក្នុងពន្ធនាគារ និងតុលាការ

វិធានការសុខាភិបាល គ្រប់គ្រងនិងដឹកនាំផ្ទាល់ដោយក្រសួងសុខាភិបាលតាមច្បាប់កូវីដ-១៩ និងអនុក្រឹត្យស្តីពីវិធានការសុខាភិបាល រួមទាំងការរក្សាគម្លាតសង្គម និងការត្រួតពិនិត្យការចេញ-ចូលនៃចំនួនប្រជាពលរដ្ឋនៅក្នុងទីតាំងមួយ អនុវត្តចំពោះកន្លែងសាធារណៈ និងស្ថាប័ននានាដូចជាពន្ធនាគារ និងតុលាការ ។[៦៧] ការឆ្លើយតបមិនដូចគ្នានៅក្នុងស្ថាប័នទាំងនេះ និងផលប៉ះពាល់ដែលបង្កជាគ្រោះថ្នាក់ដល់សិទ្ធិជាមូលដ្ឋាន បង្ហាញពីភាពមិនស៊ីសង្វាក់គ្នា និងលទ្ធផលអវិជ្ជមានដែលកើតចេញពីការផ្តល់សិទ្ធិសម្រេចចិត្តយ៉ាងទូលំទូលាយដល់អាជ្ញាធរ ដើម្បីរឹតត្បិតសិទ្ធិដែលមានវិសាលភាពទូលំទូលាយ និងមិនបានកំណត់ឱ្យបានច្បាស់លាស់ ដោយគ្មានប្រព័ន្ធណែនាំ និងត្រួតពិនិត្យផ្លូវការដែលរៀបចំឱ្យបានហ្មត់ចត់ ។

ភាពចង្អៀតណែនជាបញ្ហាធ្ងន់ធ្ងរនៅក្នុងពន្ធនាគារ អស់រយៈពេលជាច្រើនឆ្នាំមកហើយ ។ អំឡុងពេលនៃការរីករាលដាលនៃជំងឺរាតត្បាត ពន្ធនាគារនៅតែមានភាពចង្អៀតណែនខ្លាំង ឧទាហរណ៍ពន្ធនាគារនៅខេត្តកំពតត្រូវបានគេរាយការណ៍ថាមានផ្ទុកអ្នកជាប់ឃុំ ៥២២% ហើយពន្ធនាគារ

[៦៦] "ការវាយតម្លៃរហ័សលើស្ថានភាពជំងឺកូវីដ-១៩៖ ស្ថានភាពបិទខ្ទប់នៅរាជធានីភ្នំពេញ", DanChurchAid et al., នៅម៉ោង ២ ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២១ ដកស្រង់ពី៖ https://reliefweb.int/report/cambodia/covid-19-rapid-assessment-lockdown-situation-phnom-penh

[៦៧] មាត្រា ២ មាត្រា ៣ មាត្រា ៦ មាត្រា ៧ និងមាត្រា ៨ នៃអនុក្រឹត្យស្តីពីវិធានការសុខាភិបាល

ខេត្តកោះកុងត្រូវបានគេរាយការណ៍ថាមានផ្ទុកអ្នកជាប់ឃុំ ៣៦០% ក្នុងខែមិថុនា ឆ្នាំ២០២១ ។ ភាពចង្អៀតណែនគឺភាគច្រើនបណ្តាលមកពីអាជ្ញាធរ មិនសូវគោរពគោលការនៃការសន្មតថាគ្មានទោស ដែលនាំឱ្យមានការបំពាន និងការអនុវត្តការឃុំខ្លួនបណ្តោះអាសន្នច្រើនហួសហេតុពេក ។ អាជ្ញាធរ មិនបានប្រើប្រាស់វិធានការផ្លូវច្បាប់ឱ្យបានគ្រប់គ្រាន់សម្រាប់ជម្រើសផ្សេងក្រៅពីការឃុំខ្លួន និងការដោះលែងឱ្យនៅក្រៅឃុំក្នុងអំឡុងពេលជំងឺរាតត្បាត ដើម្បីកាត់បន្ថយភាពចង្អៀតណែនក្នុងពន្ធនាគារ ដែលអាចជួយបង្កើនការរក្សាគម្លាតសង្គម ដូចមានចែងក្នុងមាត្រា៧ នៃអនុក្រឹត្យស្តីពីវិធានការសុខាភិបាល ដោយអនុលោមទៅតាមគោលបំណងរបស់អនុក្រឹត្យ ដែលសំដៅការពារអាយុជីវិត និងសុខភាពរបស់ប្រជាពលរដ្ឋ ។ ជាជាងកំណត់ចំនួនអ្នកជាប់ឃុំនៅក្នុងទីកន្លែងតែមួយ អាជ្ញាធរពន្ធនាគារបានដាក់កម្រិតយ៉ាងខ្លាំងលើភ្ញៀវ និងអ្នកចូលសួរសុខទុក្ខ ដែលរួមមានមេធាវី អ្នកឃ្លាំមើលពន្ធនាគារ អង្គការមិនមែនរដ្ឋាភិបាល និងក្រុមគ្រួសាររបស់អ្នកទោស ។ ការហាមប្រាមមិនជាក់លាក់ និងមិនអាចកំណត់ទុកជាមុនបាន ដោយគ្មានភាពស៊ីសង្វាក់ និងភាពច្បាស់លាស់ទាក់ទងនឹងរយៈពេលពេលវេលា និងទីកន្លែងដែលការហាមប្រាមនេះត្រូវបានអនុវត្ត ។ ជាងនេះទៅទៀត សូម្បីតែនៅក្នុងពន្ធនាគារ ការហាមប្រាមភ្ញៀវ ឬអ្នកសួរសុខទុក្ខក៏ហាក់ដូចជាត្រូវបានគេអនុវត្តដោយរើសអើងដែរចំពោះសកម្មជនសិទ្ធិមនុស្ស និងសកម្មជនសិទ្ធិការងារ ។

ការហាមប្រាមភ្ញៀវ ឬអ្នកសួរសុខទុក្ខនៅក្នុងពន្ធនាគារ បានរំលោភលើសិទ្ធិការពារដោយរដ្ឋធម្មនុញ្ញរបស់អ្នកជាប់ឃុំ[៦៨] ដោយបានដាក់កម្រិតលើការចូលទៅប្រឹក្សាយោបល់អស់រយៈពេលជាច្រើនខែនៅក្នុងពន្ធនាគារទូទាំងប្រទេស ។ ការចូលទៅជួបអតិថិជនគឺមិនសុទ្ធតែអាចគ្រោងទុកជាមុនបាននោះទេ ហើយជួនកាលការទំនាក់ទំនងតាមទូរស័ព្ទក៏នៅមានកម្រិតខ្លាំង ។ ការរក្សាការសម្ងាត់នៃការទំនាក់ទំនងអាចត្រូវបានបំពាន ដោយសារការតម្រូវឱ្យបញ្ជូនឯកសារផ្លូវច្បាប់តាមរយៈមន្ត្រីពន្ធនាគារ ជាជាងការទំនាក់ទំនងផ្ទាល់រវាងមេធាវី និងកូនក្តី ។ មេធាវីត្រូវបានហាមប្រាមមិនឱ្យទៅជួបកូនក្តីដោយផ្ទាល់ក្នុងអំឡុងពេលនោះ បើទោះបីជាបានបង្ហាញការអនុលោមតាមវិធានការសុខាភិបាលផ្សេងទៀត រួមទាំងភស្តុតាងនៃការចាក់វ៉ាក់សាំង ការធ្វើតេស្តអវិជ្ជមានតាមរយៈការធ្វើតេស្តរហ័សរកមេរោគកូវីដ-១៩ មុនពេលចូល និងការពាក់ឧបករណ៍ការពារសុវត្ថិភាពផ្ទាល់ខ្លួន ក៏ដោយ ។ លើសពីនេះទៅទៀត ការហាមប្រាមភ្ញៀវ ឬអ្នកសួរសុខទុក្ខ អាចធ្វើឱ្យ អ្នកជាប់ឃុំបាត់បង់ឱកាសទទួលបានជំនួយផ្លូវចិត្ត និងសម្ភារៈប្រើប្រាស់ចាំបាច់ ដែលផ្តល់ដោយគ្រួសារ និងអង្គការមិនមែនរដ្ឋាភិបាល ក៏ដូចជាការកម្រិតលទ្ធភាពរបស់សង្គមស៊ីវិលក្នុងការត្រួតពិនិត្យផលប៉ះពាល់នៃកូវីដ-១៩ នៅក្នុងពន្ធនាគារ ។

[៦៨] មាត្រា៣៨ នៃរដ្ឋធម្មនុញ្ញរបស់ព្រះរាជាណាចក្រកម្ពុជា

ខណៈពេលដែលចំនួនអ្នកជាប់ឃុំនៅក្នុងពន្ធនាគារបានកើនឡើងអំឡុងពេលនៃរីករាលដាលនៃជំងឺកូវីដ-១៩ដោយសារការចាប់ខ្លួន និងអត្រាខ្ពស់នៃការឃុំខ្លួនបណ្ដោះអាសន្ន តុលាការបានលុបចោលសវនាការជាច្រើន ហើយបានបង្កឱ្យមានការពន្យារពេលយូរក្នុងដំណើរការនីតិវិធី ។ ឧទាហរណ៍ សវនាការដ៏ធំនៃសមាជិក និងថ្នាក់ដឹកនាំអតីតគណបក្សសង្គ្រោះជាតិ ចំនួន៦០នាក់ ដែលត្រូវបានចោទប្រកាន់ពីបទញុះញង់ និងបទរួមគំនិតក្បត់ ត្រូវបានពន្យារពេលអស់រយៈពេល៩ខែ បើទោះបីជាសវនាការផ្សេងទៀតនៅតែបន្តជាធម្មតា និងការពិតដែលចុងចោទចំនួន ៣នាក់ត្រូវបានឃុំខ្លួនអស់រយៈពេលជាងមួយឆ្នាំកន្លះ ។ អ្នកការពារសិទ្ធិមនុស្ស សកម្មជនដីធ្លី និងអតីតសមាជិកគណបក្សជំទាស់ជាច្រើននាក់ផ្សេងទៀតត្រូវបានគេឃុំខ្លួនអស់រយៈពេលយ៉ាងយូរ និងគ្មានការកំណត់ពេលវេលាច្បាស់លាស់ ខណៈដែលការជំនុំជម្រះរឿងក្ដីរបស់អ្នកទាំងនោះ ក៏មិនបានដំណើរការទៅមុខ ដែលអំពើនេះបានរំលោភបំពានដល់សិទ្ធិទទួលបានការកាត់ទោសឆាប់រហ័ស និងគោលការណ៍នៃការសន្មតថាគ្មានទោស ។ ចុងចោទផ្សេងទៀតដែលមិនត្រូវបានជាប់ឃុំ ក៏ជួបប្រទះនឹងការពន្យារពេលដែរ ដែលនេះជាការរំលោភបំពានលើសិទ្ធិរបស់ពួកគេក្នុងការទទួលបានការកាត់ទោសឆាប់រហ័ស ។ សំណុំរឿងឯកឧត្តម កឹម សុខា អតីតប្រធានគណបក្សសង្គ្រោះជាតិដែលត្រូវបានរំលាយ ដែលត្រូវបានចោទប្រកាន់ពីបទសន្ទិដ្ឋិភាពជាមួយបរទេស ក៏បានពន្យារពេលរយៈពេលជិត២ឆ្នាំ ក្រោមហេតុផលនៃការរីករាលដាលជំងឺកូវីដ-១៩ បើទោះបីជាមានការស្នើសុំម្ដងហើយម្ដងទៀតពីមេធាវីការពារក្ដីរបស់ឯកឧត្តម ដើម្បីឱ្យតុលាការបន្តនីតិវិធីក៏ដោយ ៕